

## សុខាភិយាចនគាថា

ពុទ្ធំសុមាលី ទិបទុត្តមោ តមោ
ហន្ត្វាន ពោធេសិធ បន្ថដំ ភជំ
មគ្គគ្គសេលម្ហិ សុខុដ្ឋិតោ ឋិតោ
សោ មំ ចិរំ បាតុ សុខំ សទា សទា ។

| | |
|---|---|
| ព្រះពុទ្ធដូចអាទិត្យ | ឧត្តមពិតជាងពួកជន |
| កំចាត់នូវមោហន្ធ | ហើយចេញចាកសព្វកិលេស ។ |
| ទ្រង់ឋិតនៅលើភ្នំ | ដ៏ឧត្តមមគ្គវិសេស |
| ដាស់សត្វជាប់កិលេស | ឲ្យភ្លឺថៃសក្នុងលោកា ។ |
| សូមទ្រង់ប្រោសគ្រប់គ្រង | យើងខ្ញុំផងរាល់វេលា |
| ឲ្យបានសុខគ្រប់គ្នា | អស់កាលយូរអង្វែងទៅ ។ |

សម្រាប់ជាធម្មទាន

បែបរៀនភាសាបាលី ភាគទី ៤

ព.ស. ២៥៥៩

ប្រាក់ ឃុន

# បែបរៀនភាសាបាលី

## ភាគទី ៤

វិធីទំនើបសម្រាប់រៀន និង បង្រៀនភាសាឞាលី

នៅកំរិតពុទ្ធិកបឋមសិក្សា

រៀបរៀងដោយ

ខ្ញុំព្រះករុណា អាត្មាភាព

**ធម្មបាលោ ប្រាក់ ឃុន**

កំណែលម្អជាថ្មី

ព.ស. ២៥៥៩ គ.ស. ២០១៥



# ធម្មបាលោ ប្រាក់ ឃុន

## ព្រះជន្មាយុ ៨៩ ឆ្នាំ

## កិត្តិបណ្ឌិតភាសាបាលី សាស្ត្រាចារ្យពុទ្ធិកវិទ្យាល័យ

# បែបរៀនភាសាបាលី

## ភាគទី ៤

វិធីទំនើបសម្រាប់រៀន និងបង្រៀនភាសាបាលី

នៅកំរិតពុទ្ធិកបឋមសិក្សា


រៀបរៀងដោយ

ធម្មបាលោ ប្រាក់ ឃុន

កិត្តិបណ្ឌិតភាសាបាលី សាស្ត្រាចារ្យពុទ្ធិកវិទ្យាល័យ



បានពិនិត្យផ្ទៀងផ្ទាត់សារជាថ្មី
នៅវត្តព្រះគន្ធកុដិ ខេត្តបាត់ដំបង

ព.ស. ២៥៥៩ គ.ស. ២០១៥

ឈ្មោះសៀវភៅ : បែបរៀនភាសាបាលី ភាគទី ៤

រៀបរៀងដោយ : ធម្មបាលោ ប្រាក់ យុន

កិត្តិបណ្ឌិតភាសាបាលី សាស្ត្រាចារ្យពុទ្ធិកវិទ្យាល័យ

ផ្នែកអក្ខរាវិរុទ្ធ

ភិក្ខុ ញាណកោសល បណ្ឌិត យ៉ន សេងយៀត

ព្រះសាកលវិទ្យាធិការរង ព.ស.ស ភ្នំពេញ

ភិក្ខុ ចូឡវរធម្មោ ហ៊ី ជីភៅ : វិនយាចារ្យ និងធម្មាចារ្យ

ភិក្ខុ ជោតបញ្ញោ ជឹម សុវណ្ណដា : វិនយាចារ្យ និងធម្មាចារ្យ

ភិក្ខុ យសបាលោ ជ័យ សុហុន : វិនយាចារ្យ និងធម្មាចារ្យ

ភិក្ខុ នាគទីបោ នាគ ទី : សមណសិស្ស

ផ្នែកកុំព្យូទ័រ

សីលធរោ ស៊ីម ជៀនលី

កោវិទោ ឡោះ សូវៀត

បោះពុម្ពលើកទី២ : ព.ស. ២៥៥៩ គ.ស. ២០១៥

# កំណែលម្អជាថ្មី

សៀវភៅ បែបរៀនភាសាបាលី ភាគទី ១ ដល់ភាគទី ៥ និងបាលីវេយ្យាករណ៍ ១ ក្បាល ដែលជាស្នាដៃរបស់ខ្ញុំព្រះករុណា អាត្មាភាព **ធម្មចារោ ប្រាក់ យ៉ុន** កំពុងតែចរាចរ ទៅក្នុងប្រទេសនិងក្រៅប្រទេស អមដំណើរដោយសម្លេងបង្រៀនវេយ្យាករណ៍ និងប្រែធម្មបទ - មង្គល - វិសុទ្ធិមគ្គ - នៅក្នុងខ្សែអាត់ និង ឌិសផង ដើម្បីឲ្យសិក្ខាកាមជាប់ចិត្តជិតអារម្មណ៍ ខំសិក្សារៀនសូត្រភាសាបាលីតរៀងទៅ ។

ដើម្បីសម្រួលដល់ការចង់ចេះដឹងភាសាបាលី របស់ព្រះសង្ឃ គ្រហស្ថ និងដើម្បីរក្សាវប្បធម៌មរតកអក្សរសាស្ត្រខ្មែរ ឲ្យគង់វង្សនិងរីកចំរើនតរៀងទៅ ។

ខ្ញុំព្រះករុណា អាត្មាភាព និងព្រះសង្ឃវត្តព្រះគន្ធកុដិ ខេត្តបាត់ដំបង ជួយឧបត្ថម្ភ ព្រមទាំងសមណនិស្សិត សិស្ស នៅខេត្ត ក្រុងដទៃទៀត ជួយឧបត្ថម្ភ **កំណែលម្អជាថ្មី** ធ្វើឲ្យ "បែបរៀនភាសាបាលី" ឲ្យមានភាពសុក្រឹត្យប្រសិទ្ធភាពពិត

ប្រាកដជាមូលដ្ឋាន នៃវប្បធម៌ព្រះពុទ្ធសាសនា និងអក្សរសាស្ត្រខ្មែរ រុងរឿង ស្ថិតស្ថេរចេរកាលយូរអង្វែងតរៀងទៅ ។

សូមថ្លែងអំណរគុណយ៉ាងប្រសើរបំផុត ចំពោះសាស្ត្រាចារ្យ វិនយាចារ្យ ធម្មាចារ្យ និស្សិត សិស្ស ដែលបានជួយឧបត្ថម្ភតាមសមត្ថភាពគ្រប់ព្រះអង្គ ជួយផ្តល់យោបល់ និងជួយកែតម្រូវ ដើម្បីធ្វើឲ្យសៀវភៅនេះ រឹងរឹតតែល្អប្រសើរឡើងទៀត ។

សូមអនុមោទនាយកផលានិសង្សនៃមហាធម្មទាន បានសម្រេចមគ្គ ផល ដល់ព្រះនិព្វាន កុំបីឃ្លៀងឃ្លាតឡើយ ។

វត្តព្រះគន្ធកុដិ ថ្ងៃ ១២ រោច ខែ ភទ្របទ ព.ស. ២៥៥៩ / គ.ស. ២០១៥

**អ្នករៀបរៀង**

**ធម្មបាលោ ប្រាក់ ឃុន**

# បុព្វកថា

នាងខ្ញុំមានសេចក្តីរីករាយ ចំពោះការសរសេរបុព្វកថានេះ ។ គឺឯកឧត្តម ឈន អៀម, អនុរដ្ឋលេខាធិការ ទទួលបន្ទុកពុទ្ធសាសនបណ្ឌិត្យ, ដែលបានប្រាប់អោយនាងខ្ញុំដឹងមុនគេ ចំពោះហេតុដែលថា ការរៀនភាសាបាលីនៅកម្ពុជា ត្រូវបានប្រព្រឹត្តទៅតាមការរៀនសូត្រចាំមាត់, ហើយដោយហេតុនេះ ត្រូវការយ៉ាងបន្ទាន់អោយមានការផ្លាស់ប្តូរក្នុងវិធីបង្រៀន ។ ការនិយាយប្រាប់នេះ បានកន្លងទៅពីរឆ្នាំហើយ តាំងពីពេលដែលនាងខ្ញុំកំពុងធ្វើការជាមួយអង្គការសហប្រជាជាតិ នៅក្នុងប្រទេសកម្ពុជាម្ល៉េះ ។

ក្រោយពេលនាងខ្ញុំបានមកធ្វើការនៅពុទ្ធសាសនបណ្ឌិត្យ នាដើមឆ្នាំ ១៩៩៦, ឯកឧត្តម ដោក ណារិន, អនុរដ្ឋលេខាធិការ ទទួលបន្ទុកពុទ្ធិកសិក្សា បានធ្វើសំណូមពរអោយនាងខ្ញុំជួយឧបត្ថម្ភថវិកាដល់កម្មវិធីបណ្តុះបណ្តាលរយៈពេលខ្លីសម្រាប់គ្រូបង្រៀនភាសាបាលី ជិត ២៥០ នាក់ ដែលមិនធ្លាប់បានទទួលការបណ្តុះបណ្តាលដ៏សមស្រប ។ នាងខ្ញុំបានឆ្លៀតយកឱកាសនោះ ពិនិត្យមើលសៀវភៅវេយ្យាករណ៍បាលីដែលមានស្រាប់ ហើយសរសេរជាភាសាខ្មែរ ។ ឯកឧត្តម ដោក ណារិន ក៏បានប្រាប់អោយនាងខ្ញុំដឹងផងដែរ អំពីសំណៅមេរៀនភាសាបាលីបែបថ្មីមួយ រៀបរៀងឡើងដោយលោក ប្រាក់ ឃុន ដែលមិនទាន់បានបោះពុម្ពផ្សាយនៅឡើយ ។ នៅក្នុងសំណៅនោះ នាងខ្ញុំបានមើលឃើញមានសក្តានុពល ដែលអាចនាំទៅកាន់ការធ្វើអោយមេរៀនភាសាបាលីបានត្រឹមត្រូវ ប្រកបដោយវិធីបង្រៀនទំនើប ។ នាងខ្ញុំ បានអង្គុយប្រជុំជាមួយលោក ប្រាក់ ឃុន និងក្រុមគ្រូបង្រៀនបាលីមកពីក្រសួងធម្មការ និងសាសនា និងមកពីពុទ្ធសាសនបណ្ឌិត្យ, ហើយបានណែនាំ

អស់លោកទាំងនោះ អំពីវិធីទំនើបបង្រៀនភាសាដល់អ្នករៀនដំបូង តាមរយៈការការតែងជាឃ្លាប្រយោគ ។ ដ៏ជាទិដ្ឋភាពមួយដែលខ្វះនៅក្នុងមេរៀនភាសាបាលីបច្ចុប្បន្ន ក្នុងប្រទេសកម្ពុជា ។ នេះគឺជាវិធីដែលព្រះតេជព្រះគុណ សាស្ត្រាចារ្យ អ.ប. ពុទ្ធទត្តះ មហានាយកត្ថេរ នៃប្រទេសស្រីលង្កា ធ្លាប់បានប្រើនៅក្នុងសៀវភៅ « The New Pali Course » ( វិជ្ជាសិក្សាភាសាបាលី បែបថ្មី ) បោះពុម្ពផ្សាយជាភាសាអង់គ្លេស ក្នុងឆ្នាំ ១៩៣៧ ដែលនាងខ្ញុំធ្លាប់បានសិក្សា និងធ្លាប់បានបង្រៀននៅក្នុងប្រទេសស្រីលង្កា និងនៅក្នុងប្រទេសអង់គ្លេសផងដែរ ។

បាលី ឬ មាគធី, ដូចដែលគេធ្លាប់ហៅពីកាលនោះ, គឺជាភាសាដែលព្រះពុទ្ធតែងបានប្រើសម្រាប់ទេសនា នៅក្នុងសតវត្សទី ៦ មុនគ្រិស្តសករាជ នៅក្នុងប្រទេសស្រីលង្កា ។ ចាប់តាំងពីពេលនោះមក អដ្ឋកថាព្រះត្រៃបិដកជាច្រើន, អត្ថបទស្តីពីទស្សនវិជ្ជាពុទ្ធសាសនាជាច្រើន, ក៏ដូចជាអត្ថបទផ្លូវលោកទាំងឡាយផងដែរ ត្រូវបានគេសរសេរជាភាសាបាលី នៅក្នុងប្រទេសឥណ្ឌា និងនៅក្នុងប្រទេសកាន់ពុទ្ធសាសនាថេរវាទ ដូចជា ស្រីលង្កា, ភូមា, សៀម, និងកម្ពុជា ។ ជាងនេះទៀត កាលណាបព្វជិតទាំងឡាយមកពីប្រទេសកាន់ពុទ្ធសាសនាថេរវាទ បាននិមន្តទៅកាន់ប្រទេសកាន់ពុទ្ធសាសនាថេរវាទមួយទៀត កាលពីអតីតកាល, ភាសាបាលី គឺជាភាសាអន្តរជាតិ ដែលបព្វជិតទាំងនោះបានប្រើ សម្រាប់ប្រាស្រ័យឆ្លើយឆ្លងគ្នា ។ ថ្វីបើភាសាបាលិ មិនត្រូវបានប្រជាជននិយាយក៏ដោយ, ក៏ភាសានេះ នៅតែជាភាសារួមរហូតមកដល់សព្វថ្ងៃនៅឡើយ, ដែលតាមរយៈភាសានេះ បព្វជិតពុទ្ធ. សាសនិកពីប្រទេសកាន់ពុទ្ធសាសនាថេរវាទ តែងប្រាស្រ័យឆ្លើយឆ្លងគ្នា ។ ជាឧទាហរណ៍ បព្វជិតមកពីស្រីលង្កា, កាលណាលោកនិមន្តទៅកាន់ប្រទេសថៃ, តែងសន្ទនាជាមួយបព្វជិតថៃ ជាភាសាបាលិ ។ ដោយហេតុនេះ ការរៀនភាសាបាលី តាមរយៈការតែងជាឃ្លា . ប្រយោគ ជួយសម្រួលដល់ការសន្ទនា, បន្ថែមទៅលើការយល់

អត្ថបទជាភាសាបាលិ ពិបុរាណកាលទៀតផង ។

សៀវភៅ « វិជ្ជាសិក្សាភាសាបាលិ » នេះ គឺជាតម្រុយមួយ នៅក្នុងប្រទេសកម្ពុជា ពិព្រោះ នេះគឺជាការខិតខំមួយជាលើកដំបូង ដើម្បីបង្រៀនបាលិដល់អ្នករៀនដំបូង តាមរយៈការតែងជាឃ្លា-ប្រយោគ ។ នាងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះលោក ប្រាក់ ឃុន និងចំពោះក្រុមគ្រូបង្រៀនបាលិដែលបានធ្វើការយ៉ាងនឿយហត់ ដើម្បីបង្កើតឡើងនូវសៀវភៅនេះ, ព្រមទាំងអំណរគុណចំពោះសម្ដេចព្រះមង្គលទេពាចារ្យ អ៊ុម ស៊ុម, អគ្គាធិការនៃពុទ្ធិក-សិក្សា, ចំពោះព្រះពុទ្ធឃោសាចារ្យ ហេង លាងហោ , នាយកពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត, និងចំពោះសម្ដេចព្រះធម្មលិខិត លាស់ ឡាយ ព្រះចៅអធិការវត្តសន្សំកុសល, ទីក្រុងភ្នំពេញ, ដែលបានពិនិត្យយ៉ាងល្អិតល្អន់នូវសំណៅចុងក្រោយ ។ នៅទីអវសាន, នាងខ្ញុំ សូមថ្លែងអំណរគុណ លោក ឱម ខែម, នាយកពុទ្ធសាសន-បណ្ឌិត្យ ដែលបានយកចិត្តទុកដាក់យ៉ាងខ្លាំង ធ្វើអោយសៀវភៅនេះ សម្រេចបោះពុម្ពបាន ។

បណ្ឌិត *ហេម៉ា គូណាតិលកេ*

ពុទ្ធសាសនបណ្ឌិត្យ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងធម្មការ និង សាសនា**
លេខ : 672 / 96 ក.ធ.ស

# លិខិតបញ្ជាការ

មន្ត្រីរាជការ នៃក្រសួងធម្មការ និង សាសនា ដូចមានរាយនាមខាងក្រោមនេះ ត្រូវបានចាត់តាំងឱ្យទៅពិនិត្យ និងសម្រេចបោះពុម្ពសៀវភៅសិក្សា « បាលីវេយ្យាករណ៍ » ជាមួយលោកស្រីបណ្ឌិត ហេម៉ា នៅសាលប្រជុំពុទ្ធសាសនបណ្ឌិត្យ ចាប់ពីថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ១៩៩៦ វេលាម៉ោង ៨ ព្រឹក តទៅ រហូតដល់ចប់ជាស្ថាពរ ។

១. លោក រស់ សាវេន
២. លោក នួច ជឹម
៣. លោក ប្រាក់ ឃុន
៤. លោក ម៉ែន ប្រាង
៥. លោក អាំ ឆន
៦. លោក អ៊ុង សុវណ្ណ
៧. លោក ជិត ជន

មន្ត្រីរាជការ ដូចមានរាយនាមខាងលើ ត្រូវអនុវត្តភារកិច្ចរៀងៗខ្លួន ឱ្យបានសម្រេចលទ្ធផលល្អប្រសើរ ។

ភ្នំពេញ ថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ ១៩៩៦
រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

ះរៀន - វណ្ណារ៉ៃ

# និវេទនកថា

គណៈកម្មការឯកទេសភាសាបាលិ បានត្រួតពិនិត្យសំណៅ « បាលិវេយ្យាករណ៍ ភាគទី ១ » របស់លោក ប្រាក់ ឃុន គ្រូពុទ្ធិកបឋមសិក្សា វត្តពោធិវាល ខេត្តបាត់ដំបង ជាពីរលើក នៅសាលប្រជុំពុទ្ធសាសនបណ្ឌិត្យ ៖

. លើកទី ១ នៅខែកញ្ញា ឆ្នាំ ១៩៩៦ ។ គណៈកម្មការបានពិនិត្យ និងសម្រេចឱ្យកាត់បន្ថយត្រង់អន្លើខ្លះ ខាងផ្នែកមេរៀនវេយ្យាករណ៍ ទុកសម្រាប់សៀវភៅ ភាគទី ២ ហើយបានសុំឱ្យលោក ប្រាក់ ឃុន រៀបរៀង កែសម្រួល និងបំពេញបន្ថែមផ្នែកលំហាត់មួយចំនួនទៀត ។ បន្ទាប់មក អង្គប្រជុំបានសម្រេចដូរឈ្មោះ « បាលិវេយ្យាករណ៍ ភាគទី ១ » នេះទៅជា « បែបរៀនភាសាបាលិ » វិញ ដើម្បីឱ្យស្របទៅនឹងមេរៀន និងលំហាត់ ក្នុងសៀវភៅនេះ ។

. លើកទី ២ នៅដើមឆ្នាំ ១៩៩៧ ។ គណៈកម្មការបានពិនិត្យឃើញថា សៀវភៅ «បែបរៀនភាសាបាលិ ភាគទី ១ » ដែលបានរៀបរៀង កែសម្រួលឡើងវិញនេះ មានលក្ខណៈសមស្របតាមវិធីទំនើបសម្រាប់រៀន និងបង្រៀនភាសាបាលិ នៅពុទ្ធិកបឋមសិក្សា នាពេលបច្ចុប្បន្ននេះ ។

គណៈកម្មការឯកទេសភាសាបាលី បានធ្វើសំណូមពរឱ្យគណៈកម្មការអភិវឌ្ឍន៍ពុទ្ធិកសិក្សា ដាក់បញ្ចូលសៀវភៅ បែបរៀនភាសាបាលិនេះ ក្នុងពួកសៀវភៅ « សម្រាប់ការសិក្សាភាសាបាលី » ក្នុងព្រះរាជាណាចក្រកម្ពុជា តទៅ ។

ភ្នំពេញ, ខែ ១៣ ខែមករា ឆ្នាំ ១៩៩៧

ជ. គណៈកម្មការឯកទេសភាសាបាលី

ម៉ែន ប្រាជ

# សេចក្ដីដកស្រង់កំណត់ហេតុ
# របស់គណៈកម្មការអភិវឌ្ឍន៍ពុទ្ធិកសិក្សា

បន្ទាប់ពីគណៈកម្មការឯកទេសភាសាបាលី បានពិនិត្យសំណៅ « *បែបរៀនភាសាបាលី ភាគទី ១* » ដែលរៀបរៀងឡើងដោយលោក ប្រាក់ យុន រួចមក គណៈកម្មការអភិវឌ្ឍន៍ពុទ្ធិកសិក្សានៃក្រសួងធម្មការ និងសាសនា បានប្រជុំគ្នាត្រួតពិនិត្យយ៉ាងម៉ត់ចត់នូវសំណៅ បែបរៀនភាសាបាលី ភាគទិ ១ នេះ នៅថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ១៩៩៧ ។ គណៈកម្មការយល់ឃើញថា :

. មេរៀនសង្ខេប លំហាត់តែង និងបំពេញពាក្យជាឃ្លា . ប្រយោគ ក្នុងសៀវភៅនេះ មានលក្ខណៈឆ្លើយតបតាមសំណូមពរ របស់សិស្សនិងគ្រូនៃសាលាពុទ្ធិកបឋមសិក្សា ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលទទួចចង់បានជាយូរមកហើយ ។

. សៀវភៅនេះ ជាជំហានដំបូង ស្របតាមទិសដៅនៃការអភិវឌ្ឍន៍ពុទ្ធិក-សិក្សា នៅក្នុងប្រទេសកម្ពុជា នាបច្ចុប្បន្ន ។

. សៀវភៅនេះ ស្របតាមសង្វាក់នៃការសិក្សាផ្នែកភាសាអន្តរជាតិផងដែរ ។

គណៈកម្មការអភិវឌ្ឍន៍ពុទ្ធិកសិក្សា បានសម្រេចបញ្ចូលសៀវភៅ *បែបរៀនភាសាបាលី* នេះ ក្នុងពពួកសៀវភៅ « សម្រាប់ការសិក្សាភាសាបាលី កម្រិតពុទ្ធិកបឋមសិក្សា ឆ្នាំទី ១ » តទៅ ។

ភ្នំពេញ, ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ជ. គណៈកម្មការអភិវឌ្ឍន៍ពុទ្ធិកសិក្សា

**ដោក ណារិន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និងសាសនា

លេខ ៣៧ / ៩៧ ក.ធ.ស

ភ្នំពេញ, ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

# សេចក្តីសម្រេច

## ស្តីពីការបោះពុម្ពសៀវភៅបែបរៀនភាសាបាលីភាគ ។

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា,
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣,
- បានឃើញព្រះរាជក្រម លេខ នស.រកម. ០១៩៦.១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា,
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ១៩៩៧,

## សម្រេច

ប្រការ ១ : អនុញ្ញាតឱ្យបោះពុម្ពសៀវភៅ បែបរៀនភាសាបាលីភាគ ។ ។

ប្រការ ២ : សៀវភៅបែបរៀនភាសាបាលីភាគ ។ ត្រូវបោះពុម្ពខ្នាត ទំហំ ១៤ x ២០,៥ ។

ប្រការ ៣ : អនុអញ្ញាតឱ្យបោះពុម្ពលើកទី ។ ចំនួន ៣.៥០០ ក្បាល ។

ប្រការ ៤ : វិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ អនុវិទ្យាល័យ [illegible] មានភារកិច្ចអនុវត្តឱ្យបាន សម្រេចលទ្ធផលល្អ តាមសេចក្តីសម្រេចនេះ [illegible]

ចម្លងជូន :

- ក្រសួងសម្តេចព្រះសង្ឃរាជទាំងពីរ [illegible]
- ឯកសារ

ពៀន-ភណ្ណារ័ត្ន

# អារម្ភកថា

ភាសាមគធៈ ឬភាសាបាលី ជាភាសាសំខាន់ក្នុងព្រះពុទ្ធសាសនា ព្រោះជាភាសាចារឹកពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ដោយសារព្រះបរមសាស្តា ទ្រង់បានសម្តែងធម៌ប្រោសវេនេយ្យជនដោយភាសាមគធៈជាច្រើន ។ គម្ពីរសំខាន់ៗផ្នែកព្រះពុទ្ធសាសនា ដូចជាព្រះត្រៃបិដក អដ្ឋកថា ដីកា ជាដើម សុទ្ធតែចារឹកដោយភាសាមគធៈទាំងអស់ ។ អ្នកមានបំណងសិក្សាគោលធម៌ព្រះពុទ្ធសាសនា ចាំបាច់ត្រូវតែចេះដឹងភាសាមគធៈ ដែលនិយមហៅថា **ភាសាបាលី** ។

សូម្បីពុទ្ធប្បញ្ញត្តិទាំងឡាយ មានការសម្តែងព្រះបាដិមោក្ខ ការឱ្យត្រៃសរណគមន៍ដល់សាមណេរ ការសូធ្យញត្តិផ្សេងៗ ក៏ត្រូវប្រើភាសាបាលី តែម្យ៉ាង ។

ដោយអាស្រ័យហេតុទាំងនេះ ទើបខ្ញុំពេញចិត្តក្នុងកិច្ចការបង្រៀន និង ការសរសេរបែបរៀនភាសាបាលីតាំងពីភាគទី១ ទី២ ទី៣ សម្រាប់ពុទ្ធិកបឋមសិក្សា ឯភាគទី៤នេះ

សម្រាប់ពុទ្ធិកមធ្យមសិក្សា ដើម្បីផ្សព្វផ្សាយជាធម្មទានដែលជាទានឈ្នះអស់ទានទាំងពួង ។

ម្យ៉ាងទៀតក្នុងឆ្នាំ ២០០៦ ខ្ញុំមានអាយុ ៨០ ឆ្នាំ ជាបុគ្គលប្រៀបដូចស្លឹក ឈើទុំមានពណ៌លឿង ប្រាកដជានឹងទៅកាន់មាត់មច្ចុរាជក្នុងពេលឆាប់ៗខាង មុខនេះមិនខាន ឯបងប្អូនកូនចៅញាតិសន្តាន គេជួយបានត្រឹមតែឈាបនដ្ឋានប៉ុណ្ណោះ ហួសពីនោះមានតែបុណ្យកុសលសីលទានទើបជា យានដ៏ប្រសើរទៅកាន់បរលោក ដរាបដល់ព្រះនិព្វាន ។

សៀវភៅបែបរៀនភាសាបាលីភាគទី៤នេះ ខ្ញុំសង្កេតឃើញថា អដ្ឋកថា ធម្មបទមានប្រយោគ សំនួនវោហារបាលីនិងវិធីប្រើសព្វល្អប្រពៃ ជាថ្វីព្រះហស្ថ របស់ព្រះពុទ្ធឃោសាចារ្យក្នុងពុទ្ធសតវត្សទី ១០ ដែលសមណសិស្សបានសិក្សាជាដំបូងបង្អស់ ចេះចាំស្ទាត់ហើយ ទើបខ្ញុំដកស្រង់យកជាឧទាហរណ៍ មករៀបរៀងទុកក្នុងទីនេះ តែបើមានកំហុសឆ្គងត្រង់កន្លែងណា សូមមេត្តាជួយកែតម្រូវដើម្បីជាប្រយោជន៍ដល់សមណសិស្សជំនាន់ក្រោយតរៀងទៅ ។

សូមរួបរួមផលានិសង្ស ដែលកើតពីការព្យាយាម
បង្រៀនសមណសិស្សអស់ ១៦ ឆ្នាំប្រែបាលីលោតប្រយោគ
គម្ពីរធម្មបទ មង្គល វិសុទ្ធិមគ្គទុកក្នុងខ្សែ អាត់ច្រើនរយខ្សែ
និងរៀបរៀងបែបរៀនភាសាបាលីបាន ៤ ភាគ ផ្សព្វផ្សាយ
ជាធម្មទាន សូមឧទ្ទិសជូនមាតាបិតា គ្រូឧបជ្ឈាយាចារ្យ
ញាតិកាទាំង ៧ សន្តាន ក្នុងវដ្តសង្សារ សូមទទួល
អនុមោទនាយកផលាមហាកុសល បាននូវឥដ្ឋ មនុញ្ញផល
គឺសម្បត្តិមនុស្ស ទេវតា និងព្រះនិព្វានកុំបីឃ្លៀងឃ្លាតឡើយ ។

# ចិរំ តិឞ្ឋតុ ពុទ្ធសាសនំ

| | | |
|---|---|---|
| សូមពុទ្ធសាសនា | ឋិតថេរយូរយារ | រុងរឿងថ្លៃថ្លា |
| | អង្វែងវែងឆ្ងាយ ។ | |
| រូបគ្រូបាត់ទៅ | កេរ្តិ៍ឈ្មោះគង់នៅ | នឹងសិស្សទាំងឡាយ |
| ដែលមានកតញ្ញូ | នឹងគ្រូបាធ្យាយ | អាចឱ្យពណ្ណរាយ |
| | នៅនាលោកីយ៍ ។ | |
| អក្សរសាស្ត្រខ្មែរ | ថ្កុំថ្កើងហូរហែ | ដោយពាក្យបាលី |
| ព្រមទាំងសំស្ក្រឹត | ជួយផ្សំសេចក្តី | មិនចេះបាលី |
| | សរសេរមិនត្រូវ ។ | |
| ព្រះធម្មវិន័យ | ពុទ្ធបញ្ញត្តិក្តី | ព្រះអង្គតម្រូវ |
| ឱ្យអានបាលី | ទើបបានត្រឹមត្រូវ | ហេតុនេះកូនចៅ |
| | ត្រូវរៀនបាលី ។ | |

វត្តដំរីស ថ្ងៃទី ០១ ខែ មិថុនា $\frac{\text{ព.ស. ២៥៥០}}{\text{គ.ស. ២០០៦}}$

# មាតិកា

**ឈ្មោះអត្ថបទ** **ទំព័រ**

១. ការតែងប្រយោគបាលី........................................... ១
២. គម្រោងនៃការតែងប្រយោគ.................................. ៧
៣.វិធីរៀងប្រយោគ.................................................... ១៥
៤. វិធីរៀងបឋមាវិភត្តិ................................................ ១៦
៥. វិធីរៀងទុតិយាវិភត្តិ................................................ ២១
៦. វិធីរៀងតតិយាវិភត្តិ.............................................. ២៦
៧.វិធីរៀងចតុត្ថីវិភត្តិ.................................................. ៣០
៨. វិធីរៀងបញ្ចមីវិភត្តិ................................................ ៣២
៩. វិធីរៀងឆដ្ឋីវិភត្តិ.................................................... ៣៥
១០. វិធីរៀងសត្តមីវិភត្តិ.............................................. ៣៧
១១. វិធីរៀងអាលបនៈ................................................ ៤០
១២. វិធីរៀងវិសេសនៈ................................................ ៤៣
១៣.វិធីរៀងកិរិយាសព្ទ................................................ ៤៦
១៤. វិធីរៀងកិរិយាវិសេសនៈ...................................... ៦២
១៥. វិធីរៀងវិកតិកត្តា.................................................. ៦៥
១៦. វិធីរៀងនិបាតសព្ទ..................................................៦៩

១៧.វិធីប្រើនាមសព្វ.................................................. ៧៩
១៨.និយមន័យ(ភាសាខ្មែរ+ភាសាបាលី)................... ១៦១
១៩. វិធីរៀងភាសាបាលី.......................................... ១៦៧
២០.កាលក្នុងអាខ្យាត............................................. ១៧៧
២១. វាចកៈ............................................................ ១៨៦
២២. បច្ច័យ........................................................... ១៩០
២៣.សម្ពន្ធ........................................................... ១៩១
២៤. លំហាត់.......................................................... ១៩៥

# ការតែងប្រយោគភាសាបាលី

ពាក្យនិយាយគ្នាក្នុងភាសាបាលី លោកចែកជា ៣ យ៉ាងគឺ ៖

១. **សព្ទ** : មួយតួក្តី ច្រើនតួក្តី ដែលមិនទាន់ផ្សំ នឹងវិភត្តិ ហៅថា **សព្ទ** មាន ៣ពួកគឺ ៖

ក. **អព្យយសព្ទ** : សព្ទដែលមិនត្រូវផ្សំនឹងវិភត្តិ បានដល់ ឧបសគ្គ, និបាត , បច្ច័យ ។

ខ. **នាមសព្ទ** : សព្ទដែលត្រូវផ្សំនឹងវិភត្តិ បានដល់ នាមនាម, គុណនាម , សព្វនាម ។

គ. **កិរិយាសព្ទ** : សព្ទជាកិរិយាដែលត្រូវផ្សំនឹងវិភត្តិ បានដល់ កិរិយាអាខ្យាត និង កិរិយាកិតក: ។ ឧទាហរណ៍ : **ភវ សុណា ករោ សុណន្ត ករោន្ត** ។

២. **បទ** : សព្ទតែមួយដូចជា **បុរិស ភាតុ នព ចីវរ** ក្តី សព្ទច្រើនដូចជា **បុត្តធីតុ ហត្ថិអស្សគោណមហីសាទិ** ក្តី បើប្រកបផ្សំនឹងវិភត្តិណាមួយ សម្រេចរូបជា **បុរិសោ ភាតោ នពំ ចីវរំ បុត្តធីតរោ ហត្ថិអស្សគោណមហីសាទយោ**

**សុណាន្តោ** យ៉ាងនេះ ហៅថា **បទ** ។

ឝ. **ប្រយោគ** : បទច្រើនៗ ឬវាក្យាង្គច្រើនៗ តាំងពីត្រឹមពីរ-បីឡើងទៅ សម្ដៅដល់ពាក្យ និយាយដែលមានន័យគ្រប់គ្រាន់ អាចស្ដាប់បាន យល់សេចក្ដីច្បាស់លាស់បាន ដូចជាភាសាខ្មែរថា : ខ្ញុំទៅធ្វើការ, គេមកអំពីវត្ត ជាដើម ហៅថា **ប្រយោគ** ។

ឯប្រយោគក្នុងភាសាបាលី នឹងរៀបរៀងថា : **អហំ គមករ កម្ម, ត អាគម អាវាស** ដូច្នេះមិនត្រឹមត្រូវទេ ព្រោះគ្មានគ្រឿងប្រដាប់សម្រាប់សម្គាល់ថាជា នាមសព្ទ ឬកិរិយាសព្ទ ។

ប្រៀបដូចជាល្ខោនត្រូវសម្ដែងរឿងអ្វី ? រឿងនោះមានតួសម្ដែងប៉ុន្មាននាក់ ? ម្នាក់ៗ ត្រូវតាក់តែងខ្លួនដោយគ្រឿងប្រដាប់អ្វីខ្លះ ? តួអង្គណាត្រូវចេញទៅសម្ដែងមុនគេ ? បើមិនតែងតួពាក់គ្រឿងប្រដាប់ទេ គេមិនអាចស្គាល់ថាជា តួព្រះរាជា ឬតួអាមាត្យជាដើមបានឡើយ ។

ផ្ទៃរឿងល្ខោនគឺជាឈ្មោះប្រយោគមួយៗ , តួអ្នកសម្ដែងគឺជាឈ្មោះ សព្ទ, គ្រឿងប្រដាប់គឺជាឈ្មោះវិភត្តិវចនៈ ជាដើម,

អ្នកចាត់ចែងឱ្យសម្តែងគឺ វិធីរៀង និងសម្ពន្ធ ។

**នាមសព្ទ** ត្រូវប្រកបដោយគ្រឿងប្រដាប់គឺ : លិង្គ , វចនៈ , វិភត្តិ ។

**កិរិយាសព្ទ** បើជាអាខ្យាត ត្រូវប្រកបដោយគ្រឿងប្រុង ៨ គឺ : វិភត្តិ, កាល ,បទ , វចនៈ , បុរិសៈ , ធាតុ , វាចក, បច្ច័យ ។ បើជាកិរិយាកិតកៈ ត្រូវប្រកបដោយគ្រឿងប្រុង ៦ គឺ : វិភត្តិ , វចនៈ , កាល , ធាតុ , វាចកៈ , បច្ច័យ ។

មុននឹងសម្តែងល្ខោន យើងត្រូវចេះរឿងល្ខោនឱ្យបានច្បាស់លាស់ ហើយតាក់តែងតួពាក់គ្រឿងប្រដាប់ឱ្យសមស្របតាមដំណើររឿង ។ ចំណែកភាសាបាលីក៏ដូច្នោះដែរ មុននឹងនិយាយ ឬសរសេរប្រយោគក្នុងភាសាបាលីត្រូវចេះអត្ថន័យនៃសព្ទនីមួយៗ ឱ្យបានច្បាស់លាស់ ព្រោះហេតុនោះ យើងអាចចែកប្រយោគក្នុងភាសាបាលីតាមលក្ខណៈវេយ្យាករណ៍ជា ៦ យ៉ាងគឺ ៖

១. ប្រយោគលិង្គត្ថៈ ដូចជា : **ធម្មោ បសាទោ** ។ **សេដ្ឋិនោ បុត្តា** ។ **អាវាសេ ភិក្ខូ** ។

២. ប្រយោគកត្តុវាចក: ដូចជា : **សោ តស្សា គព្ភបរិហារំ អទាសិ ។**

៣. ប្រយោគកម្មវាចក: ដូចជា : **អយំ ធម្មទេសនា ភគ្គ ភាសិតា ។**

៤. ប្រយោគហេតុកត្តុវាចក: ដូចជា : **អហំ តន្តេ វិបស្សនាធុរំ ម្ចុរេស្សាមិ ។**

៥. ប្រយោគហេតុកម្មវាចក: ដូចជា : **សាមិកេន សូទេន ឱទនោ បាចាបិយតេ ។**

៦. ប្រយោគភាវវាចក: ដូចជា : **ននុ អប្បមត្តេហិ ភវិតព្វំ ។**

យើងឃើញបានថា ប្រយោគលិង្គត្ថ:មានតែតួប្រធានប៉ុណ្ណោះ រីឯប្រយោគដទៃទៀតមានទាំងតួប្រធានមានទាំងតួកម្ម និងតួកិរិយាឃុំគ្រង ប្រយោគ ។

ម្យ៉ាងទៀត បើយើងសង្កេតមើលអត្ថន័យឬសាច់រឿងក្នុងប្រយោគ ហើយអាចបែងចែកប្រយោគចេញជា ៣

ប្រភេទទៀតគឺ ៖

១.ឯកត្ថប្រយោគ

២.អនេកត្ថប្រយោគ

៣.សង្ករប្រយោគ

**១. ឯកត្ថប្រយោគ** : គឺប្រយោគតូចៗ មានសេចក្តីខ្លីៗ មានបទប្រធាន បទកម្ម បទកិរិយាគ្រប់គ្រាន់ ឬមានបទពង្រីកប្រធានជាមួយកិរិយាក៏បាន ដូចជា **សោ គច្ឆតិ ។ តុម្ហេ អាហារំ តុញ្ជថ ។ តវតុ សព្វមង្គលំ ។ ពុទ្ធំ សរណំ គច្ឆាមិ ។ សាវត្ថិយំ កិរ មហាសុវណ្ណោ នាម កុដុម្ពិកោ អហោសិ អឌ្ឍោ មហទ្ធនោ មហាភោគោ អបុត្តកោ ។** ដោយសង្ខេបគឺប្រយោគដែលមានកិរិយាឃុំគ្រងពាក្យតែ មួយៗ ។

**២. អនេកត្ថប្រយោគ** : គឺប្រយោគដែលមានសេចក្តីច្រើនវគ្គតភ្ជាប់គ្នា ទើបបានន័យគ្រប់គ្រាន់ អាចដឹងអត្ថន័យច្បាស់លាស់ បានដល់ឯកត្ថប្រយោគ តាំងពីចំនួនពីរប្រយោគឡើងទៅ ដោយមាននិបាតជាតួតភ្ជាប់សេចក្តី ដូចជា **ហិ ច បន សចេ យទិ កញ្ចាបិ វា អថវា** ជាដើម ដូចជា **តន្តេ**

**អហំ មហល្លកកាលេ បព្វជិតោ គន្ថធុរំ បូរេតុំ ន សក្ខិស្សាមិ , វិបស្សនាធុរំ បន បូរេស្សាមិ ។ សចេ តេ អគរុ , វសេយ្យាម ឯករត្តឹ សាលាយំ ។ បឋមាគតោ ឥមិនា សទ្ធឹ ឯកតោ វសិតុកាមោ ភវេយ្យ វា , នោ វា ។**

ដោយសង្ខេប គឺប្រយោគដែលមានកិរិយា ឃុំគ្រងពាក្យពីរ-បីឡើងទៅ តែមានទំនាក់ទំនងសេចក្ដីជាប់តៗគ្នា ។

៣. **សង្ករប្រយោគ** : គឺប្រយោគដែលមានសេចក្ដីយោងគ្នា ជួយពង្រីកអត្ថន័យគ្នាឱ្យលេចធ្លោឡើង បានដល់ឯកត្តប្រយោគមួយ ដែលមានឯកត្តប្រយោគមួយទៀតជួយធ្វើអត្ថន័យក្នុងប្រយោគទី១ ឱ្យជាក់ច្បាស់ឡើង ដែលយើងធ្លាប់ហៅថា ប្រយោគ **យ** - **ត** នោះឯង ដូចជា :

**អន្នបានភេសជ្ជេសុ យោ យំ ឥច្ឆតិ , តស្ស តំ យថិច្ឆិតមេវ សម្បជ្ជតិ ។ យោ មំ បស្សតិ , សោ ធម្មំ បស្សតិ ។ យោ ធម្មំ បស្សតិ , សោ មំ បស្សតិ ។ យថេវ តុម្ហេ តំ ន បស្សថ តថា សោបិ តេ ពាលោ ន បស្សតិ ។**

មានប្រយោគពិសេស ២ ទៀតគឺ : ប្រយោគអនាទរៈ

១. ប្រយោគលក្ខណៈ ១ ជាប្រយោគជ្រែកចូលក្នុង

ប្រយោគធំខាងលើ មិនអាចប្រើដាច់ដោយឡែកតែម្នាក់ឯងបានទេ ។

## គម្រោងនៃការតែងប្រយោគ

ប្រយោគក្នុងភាសាបាលី ច្រើនប្រកបដោយផ្នែក សំខាន់ធំៗ ៣ គឺ : បទប្រធាន , បទកម្ម , បទកិរិយា , ក្រៅពីនោះក៏នៅមានបទពង្រីកប្រធាន, ពង្រីកកម្ម, និងបទពង្រីកកិរិយា ព្រមទាំងបទអាលបនៈនិបាតទៀត ។

ប្រយោគខ្លះ មានតែតួប្រធាន និងកិរិយា ។ ឧទាហរណ៍ : **សោ យាតិ** "គេទៅ" ។ ប្រយោគខ្លះមាន តួប្រធាន និងបទពង្រីកប្រធានមានតួកិរិយា និង បទពង្រីកកិរិយា ។ ឧទាហរណ៍ : **អញ្ញតរោ ភិក្ខុ សាវត្ថិយំ វិហាសិ** "ភិក្ខុមួយរូបនៅហើយក្នុងក្រុងសាវត្ថី" ប៉ុន្តែមិនមានតួកម្ម ក៏រាប់ថាជាប្រយោគបាន ។ ភាវវាចកៈ មានតែតួកិរិយា ឧទាហរណ៍ : **អាវាសេ ភិក្ខូ ។ សត្ថេហិ មរិតព្វំ ។**

សរុបសេចក្ដីថា ផ្នែកសំខាន់ក្នុងប្រយោគមាន ៨ យ៉ាង គឺ :

១. បទប្រធាន

២. បទពង្រីកប្រធាន

៣. បទកម្ម

៤. បទពង្រីកកម្ម

៥. បទកិរិយា

៦. បទពង្រីកកិរិយា

៧. បទអាលបនៈ

៨. និបាត

## ១. បទប្រធាន

**បទប្រធាន** : ជាចំណែកសំខាន់របស់ប្រយោគ បានដល់សព្ទដែលប្រកបដោយបឋមាវិភត្តិ ប្រែថា " រី " សូម្បីប្រយោគខ្លះមិនឃើញមានរូបបទប្រធាន ក៏ត្រូវតែដាក់បំពេញចូលមកឱ្យគ្រប់គ្រាន់ ដូចជាប្រយោគថា **សព្វំ នោគំ ទិន្នំ-យេវ ខិខរេស្ស៊ំ** ។ ប្រយោគដែលមានបទប្រធាន ដូចជា

**អថស្ស ភរិយាយ កុច្ឆិយំ គព្ភោ បតិដ្ឋាសិ ។ អយំ ធម្មទេសនា ភគ្គ ភាសិតា ។**

## ២. បទពង្រីកប្រធាន

**បទពង្រីកប្រធាន** : បានដល់បទវិសេសនៈ , វិសេស-នសព្វនាម , សញ្ញាវិសេសនៈ , សាមិសម្ពន្ធៈ និង អាធារៈ ទាំងអស់ និងបទដទៃទៀតដែលធ្វើបទប្រធាន ឱ្យមានអត្ថន័យជាក់ច្បាស់ក្រៃលែងឡើង បទពង្រីកប្រធាននេះ និយមរៀងទុកខាងមុខ (ខាងដើម) តួប្រធាន ដូចជា :

- **បទវិសេសនៈ** : **ទុក្ករំ កម្មំ មយា កតំ ។**
- **វិសេសនសព្វនាម** : **អយំ មហាជនោ កុហឹ គច្ឆតិ ។**
- **សញ្ញាវិសេសនៈ** : **សាវត្ថិយំ កិរ អនិន្ទបុព្វកោ នាម ព្រាហ្មណោ អហោសិ ។**
- **សាមិសម្ពន្ធៈ** : **តុម្ហាកំ ធីតា បុត្តំ បដិលភិត្វា កុដុម្ពស្ស សាមិនី ភវិស្សតិ ។**
- **អាធារៈ** : **តស្មឹ អាវាសេ ភិក្ខូ សន្និបតឹសុ ។**

## ៣. បទកម្ម

**បទកម្ម** : គឺបទទុតិយាវិភត្តិដែលប្រែថា " នូវ.." ហៅតាមវិធីសម្ពន្ធថា អវុត្តកម្ម ។ បទកម្មនេះត្រូវរៀងទុកខាងមុខ (ខាងដើម) កិរិយាជាសកម្មធាតុប៉ុណ្ណោះ ដូចជា **សោ តស្សា គព្ភបរិហារំ អទាសិ** ។ **សាមណេរោ តត្ថ និមិត្តំ គហេត្វា យដ្ឋិកោដឹ វិស្សជ្ជេត្វា តស្សា សន្តិកំ គតោ** ។

## ៤. បទពាក្យវិភត្តិកម្ម

**បទពាក្យវិភត្តិកម្ម** : បានដល់បទដែលធ្វើនាទីជាវិសេសនៈរបស់បទកម្ម ធ្វើបទកម្មឱ្យជាក់ច្បាស់ឡើង ទោះជានាមនាម គុណនាម សព្វនាម ឬកិរិយា ប្រកបដោយ **ត**, **អន្ត**, **មាន**-បច្ច័យ ដែលមានលិង្គ វចនៈ វិភត្តិ ស្មើគ្នានិងបទកម្ម ឬបទដទៃដែលសម្ពន្ធចូលនឹងបទកម្ម ដូចជា ៖

- **សោ ឯកទិវសំ នហានតិត្ថំ គន្ត្វា... សម្បន្នសាខំ ឯកំ វនប្បតឹ ទិស្វា** ... ។
- **សត្ថា ទ្វីហិ ជនេហិ កថិតំ កថំ បកាសេន្តោ សព្វំ មដ្ឋកុណ្ឌលិវត្ថុំ កថេសិ** ។

## ៥. បទកិរិយា

**បទកិរិយា** : គឺជាបទដែលសម្តែងអាការៈរបស់ប្រធានឱ្យមានដំណើរ ប្រព្រឹត្តទៅតាមលំដាប់ គឺជាផ្នែកសំខាន់របស់ប្រយោគ ជាគូនឹងបទប្រធាន ។ បទកិរិយាមាន ២ ប្រភេទគឺ

១. បទកិរិយាធំ (**មហាកិរិយា**)

២. បទកិរិយាតូច (**អនុកិរិយា**)

បទកិរិយាធំ ហៅថាកិរិយាឃុំគ្រងពាក្យ ឬថាកិរិយាប្រចាំប្រយោគ មានមុខនាទីគ្រប់គ្រងប្រយោគជាកិរិយាទីបំផុតរបស់ប្រយោគ យើងអាចស្គាល់ថាជាប្រយោគកត្តុវាចកៈ ឬកម្មវាចកៈជាដើមបាន ត្រូវពិនិត្យមើលកិរិយាធំ បានដល់កិរិយាអាខ្យាតទាំងអស់ និងកិរិយាកិតកៈដែលប្រកបដោយ **ត, តព្វ, អនីយ**-បច្ច័យ ។

បទកិរិយាធំនេះ ច្រើនរៀងទុកនៅទីបំផុតនៃប្រយោគដូចជា :

**សា ឧសមាសច្ចយេន បុត្តំ វិជាយិ ។ ឯវំ សម្បទមិទំ វេទិតព្វំ** ។

បទកិរិយាតូច ហៅថាអនុកិរិយា ឬអព្ភន្តរៈកិរិយា បានដល់កិរិយាកិតកៈដែលប្រកបដោយ **អន្ត**, **មាន**, **ត**, **ត្វា**-បច្ច័យជាដើម ដែលរៀងទុកនៅខាងក្នុងប្រយោគវែងៗ ឬមានកិរិយាច្រើនៗ ដូចជា ៖

**សោ ឯកទិវសំ នហានតិត្ថំ គន្ត្វា នហាត្វា អាគច្ឆន្តោ អន្តរាមគ្គេ សម្បន្នសាខំ ឯកំ វនប្បតឹ ទិស្វា** ។បេ។ **បក្កាមិ** ។

**បច្ឆា វិនយធរោ តត្ថ បវិដ្ឋោ តំ ឧទកំ ទិស្វា និក្ខមិត្វា ឥតរំ បុច្ឆិ** ។

## ៦. បទពង្រីកកិរិយា

**បទពង្រីកកិរិយា** : គឺជាបទដែលធ្វើឱ្យកិរិយាមានន័យគ្រប់គ្រាន់លេចធ្លោក្រៃលែងឡើង បានដល់បទដែលសម្ពន្ធចូលនឹងកិរិយាទាំងអស់ វៀរតែបទកម្មចេញ បានដល់សព្ទដែលប្រកបដោយ ទុតិយា តតិយា ចតុត្ថី បញ្ចមី សត្តមីវិភត្តិដែលសម្ពន្ធចូលកិរិយា និងបទកិរិយាវិសេសនៈ វិកតិកត្តា ដូចជា ៖

•ទុតិយាវិភត្តិ : (សោ) ទុក្ខី ទុម្មនោ សត្ថុ សន្តិកំ អគមាសិ ។

•តតិយាវិភត្តិ : **សោ កិរ សត្ថារិ អធិមត្តសិនេហេន បញ្ញំ ន បុច្ឆតិ ។**

•ចតុត្ថីវិភត្តិ : **សោ តំ អាហរិត្វា បុត្តស្ស តេសជ្ជំ អកាសិ ។**

•បញ្ចមីវិភត្តិ : **បាបា ចិត្តំ និវារយេ ។**

•សត្តមីវិភត្តិ : **តទា សាវត្ថិយំ សត្ត មនុស្សកោដិយោ វសន្តិ ។**

•កិរិយា-វិសេសនៈ : **សត្ថា បន តេន ហត្ថិនា ឧបដ្ឋិយមានោ សុខំ វសិ ។**

•វិកតិកត្តា : **បាបោ ជាតោសិ សាមណេរ ។**

## ៧. បទអាលបនៈ

**បទអាលបនៈ** : គឺជាបទជ្រែកចូលមកជាពាក្យហៅគ្នាក្នុងប្រយោគ វេលាប្រែត្រូវប្រែមុនបទប្រធាន មានវិធីសម្ពន្ធចំពោះតែតួឯង មិនចូលនឹងបទដទៃទេ ដូចជា :

**តន្តេ ឥមស្មិំ សាសនេ កតិ ធុរានិ ។**

**វទេហិ តាវ អាវុសោ បាលិត ។**

**អច្ឆរិយា វត ភោ ពុទ្ធគុណា ។**

## ៨. និបាត

**និបាត** : និបាតផ្សេងៗ ដែលធ្វើនាទីខាងដើមប្រយោគ ដូចជា និបាតប្រាប់កាល និបាតប្រាប់អាលបនៈ ជាដើម និបាតទាំងនេះសម្ពន្ធតែម្នាក់ឯងខ្លះ ចូលនឹងនាមខ្លះ ចូលនឹងកិរិយាខ្លះ ដូចជា ៖

- **អថស្ស ភរិយាយ កុច្ឆិយំ គព្ភោ បតិដ្ឋាសិ** ។
- **ពុទ្ធា ច នាម ធម្មំ ទេសេន្តា** ... ។
- **សាវត្ថិយំ កិរ បញ្ចសតា ធម្មិកឧបាសកា នាម អហេសុំ** ។

សូមសង្កេតមើលប្រយោគដូចតទៅនេះ ហើយប្រាប់តួនាទីរបស់បទមួយៗ ក្នុងប្រយោគ :

**ពុទ្ធា ច នាម ធម្មំ ទេសេន្តា សរណសីលបព្វជ្ជាទីនំ ឧបនិស្សយំ ឱលោកេត្វា អជ្ឈាសយវសេន ធម្មំ ទេសេន្តិ , តស្មា តំ ទិវសំ សត្ថា តស្ស ឧបនិស្សយំ ឱលោកេត្វា ធម្មំ ទេសេន្តោ អនុបុព្វីកថំ កថេសិ ។**

**ពុទ្ធោ** បទប្រធាន, **ច** និបាតផ្ដើមសេចក្ដី, **នាម** និបាត, **ធម្មំ** បទកម្ម, **ទេសេន្តោ** អព្ភន្តរកិរិយា, **សរណសីលប្បព្វជ្ជាទីនំ** បទពង្រីកកម្ម, **ឧបនិស្សយំ** បទកម្ម, **ឱលោកេត្វា** កិរិយាតូច, **អជ្ឈាសយវសេន** បទពង្រីកកិរិយា, **ធម្មំ** បទកម្ម ; **ទេសេន្តិ** កិរិយាធំ (គ្រប់គ្រងប្រយោគ កត្តុវាចក:) , **តស្មា** បទពង្រីកកិរិយា, **តំ ទិវសំ** បទពង្រីកកិរិយា, **សត្ថា** បទប្រធាន, **តស្ស** បទពង្រីកកម្ម, **ឧបនិស្សយំ** បទកម្ម, **ឱលោកេត្វា** កិរិយាតូច, **ធម្មំ** បទកម្ម, **ទេសេន្តោ** កិរិយាតូច, **អនុបុព្វីកថំ** បទកម្ម, **កថេសិ** កិរិយាធំ ។

## វិធីរៀងប្រយោគ

ការរៀបរៀងប្រយោគបាលីជាការសំខាន់ បើរៀងខុសចាកទីកន្លែង ឬខុសចាកការនិយម នឹងមានអត្ថន័យ មិនច្បាស់លាស់ ដូចជាភាសាខ្មែរថា : "ភិក្ខុឲ្យចីវរដល់សាមណេរ" ប្រែជាភាសាបាលីថា : **ភិក្ខុ សាមណេរស្ស ចីវរំ ទេតិ** បើយ៉ាងនេះ អាចប្រែថា : ភិក្ខុឲ្យចីវររបស់ សាមណេរក៏បាន ព្រោះត្រូវសម្ពន្ធថា **សាមណេរស្ស** សាមិសម្ពន្ធៈក្នុង **ចីវរំ**ៗ

អវុត្តកម្ម... ត្រូវរៀងជាថ្មីថា : **ភិក្ខុ ចីវរំ សាមណេរស្ស ទេតិ** សម្ពន្ធថា **សាមណេរស្ស សម្បទាន:** ក្នុង **ទេតិ** ។ល។ **ឥមំ កឋិនចីវរំ សង្ឃស្ស ទេម** ដូច្នេះជាដើម ។

ហេតុនេះ ការរៀបរៀងសព្ទចូលក្នុងប្រយោគភាសាបាលី ចាំបាច់ត្រូវរៀងតាមវេយ្យាករណ៍និងវិធីសម្ពន្ធ ។

## វិធីរៀងបឋមាវិភត្តិ

សព្ទប្រកបដោយបឋមាវិភត្តិ ដែលធ្វើនាទីជាបទប្រធានក្នុងប្រយោគ នោះ មានច្រើនយ៉ាងដូចតទៅនេះ :

### ១. នាមសព្ទ

ក. **នាមនាម** ដូចជា **សេដ្ឋី មនុស្ស ថេរ ហត្ថី** ។ល។

ខ. **គុណនាម** ដូចជា **បណ្ឌិត ពាល អន្ធ** ។ល។

គ. **សព្វនាម** ដូចជា **អហំ ត្វំ មយំ តុម្ហេ (បុរិស)**

ឃ. **សង្ខ្យានាម** តាំងពី ៥៥ ឡើងទៅ ដូចជា :

- **បញ្ចសុវណ្ណសិវិកាសតានិ បរិវារានិ ហោន្តិ ។**
- **បញ្ច យោធសតានិ បរិវារា** ។
- **ភិក្ខុសហស្សំ បរិវារោ អហោសិ** ។
- **អឌ្ឍរាសហស្សំ បរិវារេសិ ។**

**- ទ្វេ ភិក្ខុសហស្សានិ ភុញ្ជន្តិ ។**

**- អម្ហាកំ មយា ភិក្ខុសហស្សំ និមន្តិតំ ។**

**- តទា សាវត្ថិយំ សត្ត មនុស្សកោដិយោ វសន្តិ ។**

**- បញ្ច អរិយសាវកកោដិយោ តុម្ហាកំ អាគមនំ បច្ចាសីសន្តិ ។**

## ២. អព្យយសព្ទ

ត្ដូខ្លះធ្វើជាប្រធានបាន ដូចជា **ឥទានិ អតិសាយញ្ហោ** , **មេឃោ ច ឧដ្ឋិតោ** ។ **ភន្តេ ឥទានិ មេ នវុតិវស្សសហស្សបរិមាណស្ស អាយុនោ កោដិយំ និសីទិត្វា និទ្ទាយនកាលោ វិយ** ។ **មដ្ឋកុណ្ឌលី សោតាបន្នោ ភវិស្សតិ** , **តថា អទិន្នបុព្វកោ ព្រាហ្មណោ** ។ **សាវត្ថិយំ ហិ ទេវសិកំ អនាថបិណ្ឌិកស្ស គេហេ ទ្វេ ភិក្ខុសហស្សានិ ភុញ្ជន្តិ** , **តថា វិសាខាយ មហាឧបាសិកាយ** ។ **អលំ ឯត្តកេន ឥមស្ស** ។ **អលំ ភិក្ខវេ មា ភណ្ឌនំ** ។ **ឯវំ ភន្តេតិ** ។ **ឯវំ ភិក្ខវេតិ** ។ **អជ្ជ សត្តមោ ទិវសោ** ។

## ៣. កិរិយាសមាស

បានដល់កិរិយាសព្ទ តភ្ជាប់នឹងនាមសព្ទ និងកិរិយាអាខ្យាត ដូចជា :

**អហោសិកម្មំ នត្ថិប្ចូវោ ។**

កិរិយាកិតក: ដូចជា : **ភិក្ខវេ តទា មម បុត្តេន កតកម្មំ បច្ឆតោ បច្ឆតោ អនុពន្ធិ ។ ននុ តេ បុត្តេន មជ្ឈកុណ្ឌលិនា មយិ មនំ បសាទេត្វា អត្តនោ សគ្គេ និព្វត្តភាវោ កថិតោ ។ បសន្នេន ហិ មនេន កតកម្មំ ទេវលោកំ មនុស្សលោកំ គច្ឆន្តំ បុគ្គលំ ឆាយាវ ន វិជហតិ ។ ឥមំ នគរំ សម្បត្តបព្វជិតា កត្ថ វសន្តិ ។ សេសជនេហិ កតសស្សំ អតិឧទកេន វា អនោទកេន វា នស្សតិ ។ និព្វត្តសត្តា បនេត្ថ កម្មពលេន មាតុកុច្ឆិគតា វិយ ន វិលីយន្តិ ។**

## ៤. នាមកិតិក:

គឺកិតក:ដែលជានាមនាម ដូចជា : **ឆារណំ ភជនំ វចនំ គហនំ សវនំ គមនំ គណនា បត្ថនា គតិ សតិ ពុទ្ធោ ភាតុំ វសិតុំ ទាតុំ និសីទិតុំ ឧបសង្កមិតុំ** ។ល។

## ៥. សមាស

បានដល់សមាសនាម ដូចជា : **មហាបុរិសោ ធម្ម-ទេសនា មាតាបិតរោ ម្ចូវគន្ធោ** ។ល។

## ៦. តទ្ធិត

បានដល់តទ្ធិតនាម ដូចជា : **ភាសាវំ សាមណេរោ មេធាវី សហាយតា សីលវា ទុព្វចតាវោ** ។

## វិធីរៀងបឋមាវិភត្តិ

ការរៀងបឋមាវិភត្តិជាបទប្រធាន មិនមែនកំណត់ថា ត្រូវតែរៀងទុកជា បទទី ១ ឬទី ២ ទេ ស្រេចហើយតែ ប្រយោគវែង ឬខ្លី ។

១. បើប្រយោគតូចៗ ខ្លីៗ មិនមាននិបាតដើមសេចក្តី មិនមានបទពង្រីកបន្ថែមសេចក្តីជាដើមទេ ក្នុងប្រយោគ កត្តុវាចកៈ ហេតុកត្តុវាចកៈ ឱ្យរៀងទុកដើមប្រយោគ ដូចជា :

- **សូទោ ឱទនំ បចតិ** ។ **សាមិកោ សូទំ ឱទនំ បាចេតិ** ។ **សោ តស្សា គព្ភបរិហារំ អទាសិ** ។ **សា ទសមាសច្ចយេន បុត្តំ វិជាយិ** ។ **មនុស្សា វត្តសម្បន្នេ ភិក្ខូ ទិស្វា បសន្នចិត្តា** ។

២. ក្នុងប្រយោគកម្មវាចកៈ ហេតុកម្មវាចកៈ ឱ្យរៀង ទុកខាងក្រោយតួ អនភិហិតកត្តា ដូចជា :

- **សូទេន ឱទនោ បចិយតេ** ។

- **សាមិកេន សូទេន ឱទនោ បាចាបិយតេ** ។

- **ភន្តេ មយា តេលំ បេសិតំ ។**

- **តាត មយា សត្ថុ ធម្មទេសនា សុតា ។**

- **មយា ឯកវារេនេវ វូបសមនសមត្ថំ តេលំ បេសិតំ ។**

- **តយា មេ កុលុបច្ឆេទោ កតោ ។**

- **ឥមាហិ អត្តនោ សាមិកោ គហិតោ ។**

- **មយា ឯវរូបោ នាម បព្វជិតោ ន ទិដ្ឋបុព្វោ យេវ ។**

រៀងទុកខាងមុខ អនភិហិតកត្តា :

- **បណ្ណំ មម សហាយកេន តុយ្ហំ បេសិតំ ។**

- **កឹ បន សោ តុម្ហេហិ មារេន្តោ ទិដ្ឋោ ។**

- **ឥទានិ តាវស្ស ភន្តេ ទុព្វចភាវោ អម្ហេហិ ញាតោ ។**

- **ឥទំ អនគ្ឃកាសាវំ ឯកេន កុដុម្ពិកេន ឯវំ នាម វត្វា ទិន្នំ ។**

- **សព្វំ តុម្ហេហិ ញាតំ ។**

៣. ក្នុងប្រយោគដែលមាននិបាតដើមសេចក្ដីឬកាលត្ថសត្តមី ឬមានសព្វពង្រីកកិរិយា ដូចជា : **អថ យទិ តទា កឹ ការណា** ជាដើមនៅខាងមុខក្ដី មានបទពង្រីកប្រធានក្ដី ឱ្យរៀងទុកខាងក្រោយបទទាំងនោះ ដូចជា :

**- សចេ ត្វំ អតិក្ខមានោ អាគតោសិ ។**

**- តទា កិរ សាវត្ថិយំ សត្ត មនុស្សកោដិយោ វសន្តិ ។**

**- អថស្ស ភរិយាយ កុច្ឆិយំ គព្ភោ បតិដ្ឋាសិ ។**

**- អយំ ធម្មទេសនា ភគ្គ ភាសិតា ។**

**- តាត យំ ឥមស្មិំ កុលេ សវិញ្ញាណកាវិញ្ញាណកំ ធនំ កិញ្ចិ អត្ថិ ។**

**- ព្រាហ្មណ តវ គេហេ ពហុំ ធនំ អត្ថិ ។**

**- មយ្ហំ រត្តឹ សាលាយំ កិច្ចំ នត្ថិ ។**

**- តាតា អម្ហាកំ ពុទ្ធានំ អនុច្ឆិវិកោ ទេយ្យធម្មោ នត្ថិ ។**

**- កុហឹ កិរ សម្ម អម្ហាកំ សត្ថា វសតិ ។**

**- សាវត្ថិយំ ហិ ទេវសិកំ អនាថបិណ្ឌិកស្ស គេហេ ភិក្ខុសហស្សានិ ភុញ្ជន្តិ ។**

**- តទា បន នវវុឌ្ឍាយ ភូមិយា ពហូ ឥន្ទគោបកា ឧដ្ឋហឹសុ ។**

## វិធីរៀនទុតិយាវិភត្តិ

បទទុតិយាវិភត្តិ សម្ពន្ធចូលកិរិយាសព្ទតែម្យ៉ាងប្រែថា : “នូវ... កាន់... ញុំាង... អស់... នឹង... ចំពោះ...” ។

១. បទទុតិយាវិភត្តិ និយមរៀងទុកខាងមុខកិរិយា ដូចជា :

- **អត្តនោ សីសំ ឆិន្ទិត្វា អគ្គិនិ ឧប្បាទេត្វា ហទយមំសំ ឧព្វត្តេត្វា បុត្តទារំ បរិច្ចជិត្វា បារមិយោ បូរេន្តោ** ។ល។

- **សត្ថារំ ឧបសង្កមិត្វា ទានំ ទេហិ ធម្មំ សុណាហិ បញ្ហំ បុច្ឆាហិ** ។

រៀងទុកខាងក្រោយកិរិយាបានខ្លះ ដូចជា :

- **កោសម្ពិយំ បិណ្ឌាយ ចរិត្វា អនបលោកេត្វា ភិក្ខុសង្ឃំ** ។

- **អហំ ខោ អាវុសោ នវោ អចិរបព្វជិតោ អធុនាគតោ ឥមំ ធម្មវិនយំ** ។

- **ចណ្ឌា ខោ សាកិយា "ឥមិនា កុមារា និបាតិតាតិ" ឃាតេយ្យុំបិ មំ** ។

២. ការលំបាកក្នុងវិធីរៀងទុតិយាវិភត្តិច្រើនបទ ចូលក្នុងកិរិយាសព្ទតែមួយរួមគ្នា ឱ្យសង្កេតដូចតទៅ :

ក. អវុត្តកម្ម រួមជាមួយ ការិតកម្ម ឱ្យរៀងអវុត្តកម្ម ក្រោយការិតកម្ម (ញ៉ាំង + នូវ) ដូចជា :

- **សាមិកោ សូទំ ឱទនំ បាចេតិ** ។

- **កលហំ និស្សាយ ហិ លដុកិកាបិ សកុណា ហត្ថិនាគំ ជីវិតក្ខយំ បាបេសិ** ។

- **សចេ តន្តេ អយ្យោ ឥមស្មឹ ឋានេ ឯវំ វិហរន្តោ បព្វជិតកិច្ចំ មត្ថកំ បាបេតុំ សក្ខិស្សតិ** ។

- **អម្ហាកំ សត្ថា... ... អដ្ឋារសព្រហ្មកោដិយោ អមតបានំ បាយេន្តោ...** ។

ខ អវុត្តកម្ម រួមជាមួយ អកថិតកម្ម រៀងអវុត្តកម្មក្រោយ
. អកថិតកម្ម (នឹង ឬ ចំពោះ + នូវ) ដូចជា :

- **សត្ថារំ បព្វជ្ជំ យាចិត្វា** ... ។
- **អាគន្ត្វា កនិដ្ឋំ ឯតទវោច** ។
- **តេ សត្ថារំ ឯតទវោចុំ** ។
- **អកាលោ ខោ ឥមំ ភិក្ខុំ បញ្ហំ បុច្ឆិតុំ** ។
- **ខេត្តំ វិតជិត្វា ពហូ មនុស្សេ ហត្ថកម្មំ យាចិត្វា** ... ។
- **គច្ឆ នំ ទាយជ្ជំ យាចាហិ** ។

គ អវុត្តកម្ម រួមជាមួយ អច្ចន្តសំយោគ រៀងអវុត្តកម្ម
. ក្រោយ អច្ចន្តសំយោគ (អស់ + នូវ) ដូចជា :

- **សោ សព្វរត្តឹ សមណធម្មំ ករិត្វា** ... ។

- **អថ នំ បព្វាជេត្វា អឌ្ឍមាសមត្តំ បត្តចីវរគ្គហណា-ទីនិ សិក្ខាបេត្វា** ។

- **ទីបិនី អាគន្ត្វា តយោ វារេ បុត្តកេ ខាទិ** ។

- **តយោ វារេ អណ្ឌានិ ខាទិត្វា**... ។

- **ឯត្តកន្តរាម កាលំ ឯត្ត វសនតាវំ ជានាម** ។

- **សដ្ឋីវស្សសហស្សានិ បញ្ច សីលានិ រក្ខឹសុ** ។

- **ឯត្តកំ កាលំ តវ ទានំ បច្ចាសីសមានា**... ។

- **សេសកាលំ ពុទ្ធានំ អញ្ជលី បគ្គយ្ហ**... ។

- **ឯត្តកំ មេ កាលំ ឥមំ នត្ថិបូវន្តរាម ន បចិ** ។

- **ឥមស្មឹ អាវាសេ ឥមំ តេមាសំ វស្សំ ឧបេមិ** ។

ឃ អវុត្តកម្ម រួមជាមួយសម្បាបុណិយកម្ម ឱ្យរៀងអវុត្ត-
. កម្ម នៅមុខសម្បាបុណិយកម្ម (នូវ + កាន់) ដូចជា :

- **និពទ្ធំ យាគុភត្តំ វិហារមេវ បេសេន្តិ** ។

- **មធុបដលំ សត្ថុ សន្តិកំ ហរិត្វា** ។

- **តមេនំ ញាតយោ ទារុតេលាទីហិ សទ្ធឹ សាយំ សុសានំ នេត្វា**... ។

- **តំ តុម្ហាកំ បាទមូលំ អានេតុកាមា...** ។

- **ហត្ថតោ បត្តំ អគ្គណ្ហិត្វា ច តំ វិហារំ នេត្វា...** ។

រៀងអវុត្តកម្ម នៅពីក្រោយ សម្បាបុណិយកម្ម បានខ្លះ (កាន់ + នូវ) ដូចជា :

- **សោ មយ្ហំ សន្តិកំ កញ្ចិទេវ បហិណិស្សតិ ។**

**ង.** ការិតកម្ម រួមជាមួយ អច្ចន្តសំយោគ រៀងការិតកម្ម នៅ ក្រោយ អច្ចន្តសំយោគ (អស់ + ញុំាង) ដូចជា :

- **ទ្វេ ទារេ គព្ភំ បាតេសិ** ។

- **សត្ថាហំ មហាទានំ បវត្តេត្វា** ។

- **ឥមេ សត្ត ទិវសេ សូករេ មារេតិ** ។

**ច.** អវុត្តកម្ម រួមជាមួយបទវិកតិអវុត្តកម្ម រៀងអវុត្តកម្ម មុខ បទវិកតិអវុត្តកម្ម (នូវ + ឱ្យជា) ដូចជា :

- **ទ្វេ ទាសទារកេ តុជិស្សេ កត្វា... ។**

- **សចេ មេ អក្ខីនិ បាកតិកានិ កាតុំ សក្ខិស្សសិ ។**

- **ឥទានិ តំ អន្ធំ ករិស្សាមិ ។**

- **នេវ តេ សមគ្គេ កាតុំ អសក្ខិ ។**

- **អម្ហេ សមគ្គេ ភាតុំ ខាយមិ ។**

- **ពុទ្ធំ សរណំ គច្ឆាមិ ។**

អវុត្តកម្ម និង បទវិកតិអវុត្តកម្ម ផ្សេងវចនៈគ្នាក៏បាន ដូចជា :

- **តេនហិ ខេត្តំ ទ្វេ កោដ្ឋាសេ កត្វា មម កោដ្ឋាសំ អនាមិសិត្វា ។**

- **នន្ទោ សត្ថារា ទេវច្ឆរា អាមិសំ កត្វា ទិនីតោ ។**

- **តំ សុត្វា តុម្ហេទេវេ អាទី កត្វា ។**

## សរុបការរៀនទុតិយាវិភត្តិ

១. បទទុតិយាវិភត្តិ មករួមគ្នាច្រើនបទឱ្យរៀងបទអវុត្តកម្ម (នូវ) ទុកខាងមុខ បទសម្បាបុណិយកម្ម (កាន់) និង បទវិកតិកម្ម (ឱ្យជា) ក្រៅពីនោះ ឱ្យរៀងបទ អវុត្តកម្មទុកខាង ក្រោយដូច្នេះ ៖

នូវ + កាន់ , នូវ + ឱ្យជា ឬ ថាជា.

ញុំាង + កាន់ , អស់ + នូវ , នឹង ឬ ចំពោះ + នូវ ។

## រៀនតតិយាវិភត្តិ

បទតតិយាវិភត្តិ សម្ពន្ធចូលនាម កិរិយា និងអព្យយសព្ទ

១. និយមរៀងទុកខាងមុខបទដែលខ្លួនពង្រីក និងសម្ពន្ធចូលនោះ ដូចជា :

- **ន មេ ឯតាយ ឥន្ទតិយា អត្ថោ ។**

- **អត្ថិ នុ ខោ មយ្ហំ ឯត្ថ គតប្បច្ចយេន អត្ថោ ។**

- **តេ ឧយប្បត្តេ យវពន្ធនេន ពន្ធឹសុ ។**

- **សោ ធម្មេន វជ្ជំ ភាវេសិ ។**

- **ព្រាហ្មណស្ស សកលសរីរំ បីតិយា បរិបូរិ ។**

- **អម្ហ តយា កតសស្សំ នេវ អច្ចោទកេន នស្សតិ ន អនោទកេន នស្សតិ ។**

រៀងខាងក្រោយបទដែលខ្លួនត្រូវពង្រីកសេចក្តីក៏មាន:

- **អហំ ខោ អាកិណ្ណោ វិហរាមិ ហត្ថីហិ ហត្ថិនីហិ ហត្ថិកលភេហិ ។**

២. បទអនភិហិតកត្តា (គឺ... ដែល...) រៀងទុកខាងមុខ ឬ ខាងក្រោយបទ ប្រធានក៏បាន ដូចជា :

- **តយា មេ កុលុបច្ឆេទោ កតោ ។**

- **តុម្ហេហិ គោមាសំ ឯកកេហិ តិដ្ឋន្តេហិ និសីទន្តេហិ ច ទុក្ករំ កតំ ។**

- **ភន្តេ ញាយំ មយា សត្តាហំ បុប្ផច្ឆត្តំ ធារេន្តេន សក្ការោ កតោ ។**

- **កឹ បន សោ តុម្ហេហិ មារោន្តោ ទិដ្ឋោ ។**

- **កិន្នាមេតំ សត្ថារា កតំ ។**

- **ឯវរូបំ ករោន្តេន ភារិយំ តយា កតំ ។**

៣. បទតតិយាវិភត្តិនៅរួមបទទុតិយាវិភត្តិ នឹងរៀងបទណាមួយខាងមុខ, ខាងក្រោយក៏បាន ដូចជា :

- **តុម្ហេ មម វចនេន ទសពលញ្ច អសីតិមហាថេរេ ច វន្ទថ ។**

- **ធនច្ឆេទភយេន មម ភេសជ្ជំ អការេត្វា ។**

- **អយំ តវ ឥស្សរិយភយេន គព្ភបាតនភេសជ្ជំ យោជេត្វា ទេតិ ។**

- **សត្ថារញ្ច មហាថេរេ ច ថេរស្ស វចនេន វន្ទិត្វា ។**

- **ន ខោ បន មំ សណ្ហេន សមុទាចរិស្សតិ ។**

- **បគ្ឃរន្តំ លោហិតំ ភាជនេន បដិគ្គហេត្វា មំសំ លោហិតេន មទ្ទិត្វា ។**

៤. បទតតិយាវិភត្តិសម្ពន្ធចូល **កឹ** ឬ **អលំ** ឱ្យរៀងទុកខាងក្រោយ **កឹ** ឬ **អលំ** ដូចជា :

- **កឹ មេ យាវាសេន ។ អលន្តេ ឥធ វាសេន ។**

- **កិន្តេ សល្លក្ខិតំ ។ អលំ ឯត្តកេន ឥមស្ស ។**

- **អលំ តេ ឯត្តកំ ជីវភាយ ។**

៥. គតិយាវិភត្តិជាឥត្ថម្ភូត " មាន " រៀងទុកក្រោយបទប្រធានខាងមុខកិរិយាធំ , ឯឥត្ថម្ភូតកិរិយា រៀងក្រោយឬមុខឥត្ថម្ភូតនាមក៏បានដូចជា :

- **តំខណញ្ញេវ រាជា ឧក្កាហិ ធារិយមានាហិ គត្ថគន្ធា ។**

- **សោ ឯកស្មឹ ខាណុមត្ថកេ បតិត្វា និព្វុទ្ធគត្តោបសន្នេន ចិត្តេន កាលំ កត្វា ។**

- **សោ រោគមានោ... ហាគយេន ផលិតេន កាលំ កត្វា ។**

- **សាបិ តំ សុត្វា ឧគកពិន្ទូហិ បគ្ឃរន្តេហេវ អឡ្ហល្លិខិតេហិ កេសេហិ ទេគេន គន្ធា ។**

- **មនសា ចេ បសន្នេន ភាសតិ វា ករោតិ វា ។**

៦. គតិយាវិភត្តិជាសហាត្ថគតិយាចូលជាមួយ **សហ** ឬ **សទ្ធឹ** ឲ្យរៀងទុកខាងមុខ **សទ្ធឹ** , ខាងក្រោយ **សហ** ដូចជា :

- **អហំ ទុព្វលោ , មយា សទ្ធឹ គច្ឆន្តស្ស តវ បបញ្ចោ ភវិស្សតិ ។**

**- ភិក្ខូ សហ បដិសម្ភិទាហិ អរហត្តំ បាបុណឹសុ ។**

**- បាបកំ ចិត្តំ ឧប្បាទេត្វា សហ ចិត្តុប្បាទេន ឥទ្ធិតោ បរិហាយិត្វា ។**

**- សរីរំបិ អត្តនា សទ្ធឹ ន គច្ឆតិ ។**

**- អថស្ស អាហារេនេវ សទ្ធឹ គព្ភបាតនភេសជ្ជំ អទាសិ ។**

## សេចក្ដីសង្ខេប តតិយាវិភត្តិ

១. ពង្រីកសេចក្ដីបទណា រៀងទុកមុខបទនោះ ។

២. មករួមជាមួយទុតិយា រៀងទុកមុខបទទុតិយាវិភត្តិ ។

៣. បទអនភិហិតកត្តា រៀងទុកមុខបទប្រធានច្រើនជាង ។

៤. បើពង្រីក **ភី-អលំ** រៀងទុកក្រោយ **ភី-អលំ** ។

៥. បទឥត្ថម្ភូតៈ រៀងទុកក្រោយប្រធាន មុខកិរិយា ។

៦. សហាត្ថតតិយា រៀងទុកមុខ **សទ្ធឹ** តែក្រោយ **សហ** ។

## វិធីរៀងចតុត្ថីវិភត្តិ

បទចតុត្ថីវិភត្តិច្រើនធ្វើនាទីពង្រីកសេចក្ដីបទកិរិយាសម្ពន្ធចូលកិរិយា តែម្យ៉ាង ។

១. រៀងទុកមុខកិរិយាទូទៅ ដូចជា :

- **បារមិយា ប្ញូរន្តោ បរសេំ ធម្មទេសនត្ថមេវ ប្ញូរេតិ ។**

- **ឥត្ថី ឧប្បន្នេ ឥស្ស ករថេយ្យាម ។**

- **អថ តេ គន្ត្វា តថាគតស្ស អារោចេសុំ ។**

២. រួមជាមួយបទអវុត្តកម្ម រៀងទុកមុខឬក្រោយក៏បាន តែបើរៀងទុកក្រោយបទអវុត្តកម្ម សេចក្តីច្បាស់លាស់ជាង ។

- **សោ តំ អាហរិត្វា បុត្តស្ស តេសជ្ជំ ករោតិ ។**

- **អថ នំ ទេវទត្តស្ស អទំសុ ។**

- **អានន្ទត្ថេរោ អន្តនោ ជីវិតំ សត្ថុ បរិច្ចជិត្វា ។**

៣. រួមជាមួយសម្បាបុណិយកម្ម ឬបទអាធារៈរៀងទុកក្រោយបទទាំងពី (កាន់ + ដើម្បី. ក្នុង + ដើម្បី) ដូចជា :

- **តេ និពទ្ធំ តមេវ គាមំ បិណ្ឌាយ បវិសន្តិ ។**

- **យត្ថ ថេរស្ស កនិដ្ឋោ វសតិ, តំ វិថឹ បិណ្ឌាយ បវិសឹសុ ។**

- **រាជគហំ គន្ត្វា តត្ថ (រាជគហេ) បិណ្ឌាយ ចរិត្វា...។**

- **អាយស្មន្តំ អានន្ទត្ថេរំ រាជគហេ បិណ្ឌាយ ចរន្តំ ទិស្វា... ។**

- **សោ ញាតិសមាគមេយេវ បិណ្ឌាយ ចរតិ ។**

## សេចក្ដីសង្ខេបចតុត្ថីវិភត្តិ

១. ពង្រីកសេចក្ដីបទណា រៀងទុកខាងមុខបទនោះ ។

២. រួមជាមួយបទទុតិយា, សត្តមីវិភត្តិ រៀងទុកខាងមុខអវុត្តកម្មខ្លះ តែរៀងទុកក្រោយបទសម្បាបុណិយកម្ម និងអាធារៈ ដល់ + នូវ , កាន់ + ដើម្បី , ក្នុង + ដើម្បី ។

## វិធីរៀងបញ្ចមីវិភត្តិ

បទបញ្ចមីវិភត្តិ ធ្វើនាទីពង្រីកកិរិយា និងនាម បើពង្រីកបទណាឲ្យរៀងទុកខាងមុខបទនោះដូចជា :

- **ពារាណសិតោ អវិទូរេ សត្តសិរីសរុក្ខា អត្ថិ ។**

- **នវហិ វណ្ណមុខេហិ បុព្វវឌ្ឍិយោ ចេវ បុឡវាច បត្ថរីសុ ។**

១. នៅខាងមុខបទដែលពង្រីកជានិច្ច ដូចជា :

- **មយំ ហិ ធរមានស្ស ពុទ្ធស្ស សន្តិកា កម្មដ្ឋានំ គហេត្វា ។**

- **ឆិទ្ទឃដតោ ឧទកធារា វិយ អគ្គីហិ ធារា បត្ថរន្តិ ។**

២. រួមជាមួយទុតិយាវិភត្តិ រៀងទុកខាងមុខ ឬក្រោយក៏បាន

- **អថេកោ ទិសាវាសិកោ ភិក្ខុ រាជគហា សាវត្ថឹ គន្ត្វា ។**

- **ទេវលោកេ និព្វត្តិ ទេវលោកា ទេវលោកំ សំសរន្តោ ។**

- **តេ ទូរតោ វ ទិស្វា ភិក្ខូ អាមន្តេសិ ។**

- **អហមេវ សមណំ គោតមំ ជីវិតា វោរោបេស្សាមិ ។**

- **រាជា សេនាបតឹ រដ្ឋតោ បព្វាជេសិ ។**

៣. រួមចូលនិបាតសព្ទគឺ **យាវ វិនា អញ្ញត្រ** រៀងទុកខាងក្រោយនិបាតទាំងនោះ ដូចជា :

- **យាវ អកនិដ្ឋភវនា បន ឯកនិន្នាទំ កោលាហលំ អគមាសិ ។**

- **សោ អនុក្កមេន យាវ គោប្ផកា យាវ ជន្នុកា យាវ ថនតោ យាវ គីវតោ បវិសិត្វា ។**

- **ន មយំ វិនា ភិក្ខុសង្ឃេន វត្តាម ។**

- **អជ្ជតគ្គេ ទានាហំ អាវុសោ អានន្ទ អញ្ញត្រេវ ភគវតា អញ្ញត្រ ភិក្ខុសង្ឃេន ឧបោសថំ ករិស្សាមិ ។**

២. បើរួមចូលនិងនិបាតគឺ **ឧទ្ធំ នានា បដ្ឋាយ** ឲ្យរៀងបទបញ្ចមីវិភត្តិទុកខាងមុខនិបាតទាំងនេះ ដូចជា :

- **តតោ ឧទ្ធំ កិញ្ចិ គយ្ហុបគំ នត្ថិ ។**

- **មតេន តេ ភី នានាករណា ច ហោន្តិ ។**

- **សាបិ តតោ បដ្ឋាយ សព្វេសំ កម្មន្តំ ឱលោកេន្តី ។**

៥. បទហេតុគឺ **យស្មា តស្មា កស្មា កឹការណា** ឲ្យរៀង ទុកដើមសេចក្តី ដូចជា :

- **យស្មា សោ ន តថាភាសិ, តស្មា ឯវមាហ , កស្មា មយ្ហំ គព្ភស្ស បតិដ្ឋិតភាវំ ន កថេសិ កឹការណា យដេសិ យដេសិ កឹការណា យដេសិ... ។**

បើ **យស្មា តស្មា** មកជាគូនឹងបទកាលត្តសត្តមី ឬនិង និបាតគឺ **យថា** ឲ្យរៀង **យស្មា តស្មា** ទុកខាង មុនដូចជា :

- **តស្មា តំទិវសំ សត្ថា តស្ស ឧបនិស្សយំ ឱលោកេត្វា... ។**

- **តស្មា យថា កណ្ដកោ ផលានិ គណ្ហន្តោ** ។ល។ **សោបិ អត្តនោ ឃាតាយ ផល្លតិ ។**

- **អថ កស្មា ឯវមភាសិ ។**

## សេចក្តីសង្ខេបបញ្ចមីវិភត្តិ

១. ធ្វើនាទីពង្រីកបទណា ឲ្យរៀងទុកខាងមុខបទនោះ ។

២. មករួមនិងបទទុតិយារៀងទុកខាងមុខ ឬក្រោយ ទុតិយាក៏បាន ។

៣. រៀងទុកក្រោយនិបាត **យាវ វិនា អញ្ញត្រ** , តែរៀងទុក ខាងមុខនិបាត **ឧទ្ធំ នានា បដ្ឋាយ** ។

៤. **យស្មា តស្មា កស្មា កឹការណា** រៀងទុកដើមប្រយោគ ។

## វិធីរៀងឆដ្ឋីវិភត្តិ

បទឆដ្ឋីវិភត្តិ ជាបទពង្រីកនាម សម្ពន្ធចូលបទណា ឲ្យរៀងទុកមុខបទនោះ ។

១. រៀងនៅមុខបទដែលពង្រីកជានាម ដូចជា :

- **អម្ហាកំ ឯកំ កិច្ចំ អត្ថិ ។**
- **អថាហំ មយ្ហំ ទោសោ នត្ថិ, យស្ស ទោសោ អត្ថិ, តស្សេវ ឧបរិ សោបោ បតតូតិ វត្វា ។**

២. ប្រយោគអនាទរៈ ជាប្រយោគជ្រែកចូល ត្រូវរៀងទុកផ្សេងដោយឡែកដូចជា :

- **តស្ស វិរវន្តស្សេវ សត្ថុ សន្តិកំ គន្ត្វា ។**
- **ថេរស្ស និទ្ធំ អនោក្កមន្តស្ស បឋមមាសេ អតិក្កន្តេ, អក្ខិរោគោ ឧប្បជ្ជិ ។**
- **អាចរិយ មយ្ហំ ទោសោ នត្ថិ, មម វទន្តស្សេវ តុម្ហេ អតិសបិត្ថ ។**

- **បស្សន្តស្សេវ សរទតាបសស្ស អាកាសតោ ឱតរិត្វា ។**

៣. បទថា **តេ មេ , វោ នោ** មិនរៀងដើមប្រយោគទេ

- **ព្រាហ្មណ បុត្តស្ស តេ រោគោ ឧប្បន្នោ ។**

- **អស្សុកេន មេ បក្កំ ។**

- **មា វោ អាវុសោ ឯវំ រុចិត្ថ ។**

- **អយ្យោ នោ គន្ត្វេ ឥមស្មឹ ឋានេ វិហរតិ ។**

- **តេសង្ឃន្តេ គរិស្សាម ។**

- **តុម្ហេបិ នោ បុរិមសទិសា វ ហោថ ។**

៤. **វោ នោ នេសំ** មិនមានបទដទៃនាំមុខឲ្យរៀង ទុកក្រោយបទនិទ្ធារណីយៈ ដូចជា :

- **សចេ បន វោ ឯកោបិ អប្បមត្តោ អគវិស្ស ។**

- **កោ នីធ កន្ថតំ ពាលក្យតរោ ។**

- **ឯកោបិ ច នេសំ អប្បមាទំ នាបជ្ជិ ។**

## សេចក្ដីសង្ខេបឆដ្ឋីវិភត្តិ

១. បទសាមិសម្ពន្ធៈ រៀងទុកខាងមុខបទជានាមនាម ។

២. បទ **តេ , វោ** មកពី **តុម្ហ** និង **មេ នោ នេសំ** មិនរៀងនៅដើមប្រយោគទេ ។

៣. **តេ** មកពី **ត** និង **នោ** និបាតបដិសេធរៀងខាងដើមបាន ។

## វិធីរៀងសត្តមីវិភត្តិ

បទសត្តមីវិភត្តិ សម្ពន្ធចូលនាម ចូលកិរិយា

១. ធ្វើនាទីពង្រីកបទប្រធាន ឲ្យរៀងដើមប្រយោគ ឬនៅមុខបទដែលពង្រីក ដូចជា :

- **ចក្ខុសុ សមុទ្ទេសុ ជលំ បរិត្តំ** ។
- **ឯកិស្សា ឥត្ថិយា គីតសទ្ទំ សុត្វា សរេ និមិត្តំ គណ្ហិ** ។

២. ពង្រីកកិរិយា ឲ្យរៀងទុកខាងមុខកិរិយា ដូចជា :

- **សត្ថា ជេតវនមហាវិហារេ វិហរតិ** ។

៣. បើមកប្រួមបទអវុត្តកម្មឲ្យរៀងទុកមុខ បទអវុត្តកម្ម នោះ

- **វត្តសម្បន្នា ហិ តរូនំ សយនេ វា អាសនេ វា អត្តនោ បរិក្ខារំ ន ឋបេន្តិ** ។

៤. កាលត្ថសត្តមី គ្រប់សេចក្តីទូទាំងប្រយោគឲ្យរៀងទុកដើមប្រយោគ ឬទីពីរនៃប្រយោគ ដូចជា :

- **តស្មឹ សមយេ សត្ថា បវត្តិតប្បវរធម្មចក្កោ អនុបុព្វេន...** ។

- **តទា សាវត្ថិយំ សត្ត មនុស្សកោដិយោ វសន្តិ ។**

៥. កាលត្ថសត្តមីមកពីនិបាតគឺ **អថ** មកពីបច្ច័យគឺ **តទា យថា ឥទានិ** ជាដើមឲ្យរៀងនៅដើមប្រយោគ ដូចជា :

- **អថស្ស ភរិយាយ កុច្ឆិយំ គព្ភោ បតិដ្ឋាសិ ។**

- **តទា សាវត្ថិយំ សត្ត មនុស្សកោដិយោ វសន្តិ ។**

៦. កាលត្ថសត្តមីរួមគ្នាច្រើនបទ ឲ្យរៀងកាលធំខាងមុខកាលតូច តាមលំដាប់សម័យ... ឆ្នាំ... ខែ... ថ្ងៃ... ដូចជា :

- **តំទិវសំ បន សត្ថា បច្ចូសកាលេ លោកំ វោលោកេន្តោ... ។**

- **ហិយ្យោ សាយំ កុម្ភការសាលំ អាគតា ទេវ ។**

- **អថ សាយណ្ហសមយេ ភិក្ខូ ឥតោ ចិតោ ច ។**

៧. វេសយិកាធារៈ រួមគ្នាច្រើនបទ ឲ្យរៀងទីធំទូលាយជាងគេនៅខាងមុខទីតូចៗ ដូចជា :

- **ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ... ។**

- **កោសម្ពិយំ ហិ ឃោសិតារាមេ បញ្ចសតបញ្ចសតបរិវារា ទ្វេ ភិក្ខូ ។**

៨. បើសំដៅទីនៅនៃមនុស្សច្រើននាក់ដូច ស្រុក ខេត្ត ក្រុង ឲ្យរៀងទុកដើមប្រយោគ ដូចជា :

- **សាវត្ថិយំ កិរ អនិន្ទបុព្វកោ នាម ព្រាហ្មណោ អហោសិ ។**

- **តទា សាវត្ថិយំ សត្ត មនុស្សកោដិយោ វសន្តិ ។**

៩. បើសំដៅទីនៅផ្ទាល់ខ្លួនដូច កុដិ វិហារ ផ្ទះ រោង ឲ្យរៀងខាងមុខកិរិយា ដូចជា :

- **តទាបិ សត្ថា គន្ធកុដិយំ និសិន្នោ... ។**

- **អាយស្មា ហិ មហាកស្សបោ បិប្ផលិគុហាយំ វិហរន្តោ... ។**

១០. ប្រយោគលក្ខណៈមានជ្រែកចូលត្រង់ណាឲ្យរៀងត្រង់នោះ :

- **ត្វំ មេ មាតរិ មតាយ មាតា វិយ, បិតរិ មតេ បិតា វិយ លទ្ធោ ។**

- **បឋមមាសេ អតិក្កន្តេ, អគ្គិរោគោ ឧប្បជ្ជិ ។**

១១. ប្រយោគនិទ្ធារណៈ ឲ្យរៀងខាងមុខជិតបទនិទ្ធា-រណីយដូចជា :

- **តេសុ អនាថបិណ្ឌិកេន ឯកមេវ ទិវសំ សត្ថារំ បញ្ហោ... ។**

- **សម្ម កោលិត អម្ហេសុ យោ បឋមំ អធិគច្ឆតិ... ។**

- **ន ហិ សក្កា អម្ហេសុ ឯកេន អបព្វជិតុំ ។**

## សេចក្តីសង្ខេបសត្តមីវិភត្តិ

១. ពង្រីកបន្ថែមបទណា ឲ្យរៀងទុកខាងមុខបទនោះ ។

២. មករួមនិងបទអវុត្តកម្ម រៀងទុកខាងមុខអវុត្តកម្ម ។

៣. កាលត្តសត្តមីប្រាប់កាលធំគ្រប់ប្រយោគនិងមកពីអព្យយសព្ទគឺ **អថ**, **តទា**, **តទានិ**, ជាដើមឲ្យរៀងទុក ដើមប្រយោគ ។

៤. កាលធំ រៀងទុកខាងមុខកាលតូចតាមលំដាប់ ។

៥. វេសយិកាធារៈទីនៅធំទូលាយ រៀងទុកដើមប្រយោគទីនៅតូចៗ ផ្ទាល់ខ្លួន រៀងទុកខាងមុខបទដែលខ្លួនពង្រីក ។

## វិធីរៀងអាលបនៈ

អាលបនៈ គឺជាពាក្យហៅរកគូសន្ទនា ប្រើបានតែក្នុងប្រយោគលេខក្នុងប៉ុណ្ណោះ ជានាមប្រកបបឋមាវិភត្តិ និង ជានិបាតសព្ទ អាចរៀងទុកទី១ ទី២ ទី៣ ខាងដើម ឬខាងចុងបំផុតនៃប្រយោគតាមគួរដល់សេចក្តី ។

១. ក្នុងប្រយោគទូទៅ រៀងទុកដើមប្រយោគ ដូចជា :

- **ភន្តេ សចេ អយ្យា ឥមំ តេមាសំ ឥធ វសេយ្យុំ ។**
- **ភោតិ សចេ វេជ្ជំ អានេស្សាមិ ។**
- **ភទ្ទេ អហំ សមណំ គោតមំ និមន្តេត្វា បញ្ហំ បុច្ឆិស្សាមិ ។**
- **កុដជដិល អញ្ញតោ អាគន្ត្វា មម ជដាសុ អក្កមសិ ។**
- **មហារាជ នាយំ យថាមនេន ខមាបេមិ ។**
- **អជ្ជតគ្គេទានាហំ អាវុសោ អានន្ទ អញ្ញត្រេវ ភគវតា... ។**

២. ប្រយោគសន្ទនា សួរ-ឆ្លើយខ្លីៗ រៀងទុកចុងបំផុត ដូចជា :

- **កិមេតំ ភន្តេ ។ អាម ឧបាសកា ។**
- **កុហឹ យាសិ ឧបាសក ។ សាវត្ថិយំ ភន្តេ ។**
- **យាហិ អាវុសោ ។**
- **បាបោ ជាតោសិ សាមណេរ ។**
- **ខីណាសវានំ មរណចេតនា នាម នត្ថិ ភិក្ខវេ ។**
- **ហិយ្យោ សាយំ កុម្ភការសាលំ អាគតា អត្ថិ ទេវ ។**
- **កនិដ្ឋោ មេ អត្ថិ ភន្តេ ។**

- **អជ្ជហិ បរិក្ខិបិត្វា គហិតោ ភី ករិស្សតិ ភន្តេ ។**

៣. អាលបនៈនាមរួមជាមួយអាលបនៈនិបាត រៀង អាលបនៈនាមទុកខាងក្រោយ ដូចជា :

- **ចទេហិ តាត អាវុសោ បាលិត ។**

- **អាវុសោ ទុព្វិនីត មហល្លក អត្តនោ បមាណំ ន ជានាសិ ។**

- **ហន្ទ ភណេ ឧបាលិ និវត្តស្សុ ។**

- **ភោ គោតម តុម្ហាកំ ទានំ អទត្វា បូជំ អកត្វា ។**

និបាតដើមសេចក្តីមករួមជាមួយអាលបនៈ និងរៀង និបាតនោះមុខឬ ក្រោយអាលបនៈក៏បានព្រោះបាលីមិនរាប់ អាលបនៈ ថាជាបទមួយទេ ដូចជា :

- **ភន្តេ សចេ អយ្យា ឥមំ តេមាសំ ។**

- **សចេ ភន្តេ បឋមុបគតោ រោចេស្សតិ ។**

- **ភោតិ សចេ ចេដ្ឋំ អានេស្សាមិ ។**

- **ភន្តេ អយ្យស្ស ភិរ អក្ខី វាតោ វិជ្ឈតិ ។**

- **ព្រាហ្មណ បុត្តស្ស តេ រោគោ ឧប្បន្នោ ។**

- **ភោ គោតម អធិវាសេហិ មេ អជ្ជត្តនាយ ភត្តំ... ។**

## សេចក្ដីសង្ខេបអាលបនៈ

១. តាមធម្មតា អាលបនៈរៀងទុកដើមប្រយោគ ។

២. ប្រយោគសួរ-ឆ្លើយខ្លីៗ រៀងទុកខាងចុងបំផុត ។

៣. អាលបនៈមិនរាប់ថាជាបទទេ បទណាត្រូវរៀងដើមប្រយោគ ឬទី២ ទី៣ មិនត្រូវរាប់អាលបនៈឡើយ ។

## វិធីរៀងវិសេសនៈ

**វិសេសនៈ** បានដល់បទគុណ និងវិសេសនសព្វនាម ។

**បទគុណ** គឺគុណនាម សំខ្យាគុណ សមាសគុណ តទ្ធិតគុណ ។

**កិតកគុណ** វិសេសនសព្វនាម ទាំងនិយម ទាំងអនិយម ។

**បទគុណ** និងវិសេសនសព្វនាម ហៅថា បទវិសេសនៈ ។

១. បទវិសេសនៈរបស់នាមណា ត្រូវមានលិង្គ វចនៈ វិភត្តិ ស្មើគ្នានឹងនាមនោះ ដូចជា :

- **អថេកោ ទិសាវាសិកោ ភិក្ខុ រាជគហា សាវត្ថឹ គច្ឆន្តោ... ។**

**- អថេកា ទិសាទាសិកា ភិក្ខុនី សាវត្ថឹ គច្ឆន្តិ ។**

**- អថេកំ ទិសាទាសិកំ កុលំ សាវត្ថឹ គច្ឆន្តំ ។**

**- តស្មឹ ខណេ ឆហិ ទេវលោកេហិ សព្វាលង្ការប្បដិមណ្ឌិតា សហស្សសិន្ធវយុត្តា ច រថា អាគមឹសុ ។**

២. វិសាមញ្ញវិសេសនៈ ដែលសំដែងយស , ឋានៈ តំណែងត្រកូល គុណវិសេស ឲ្យរៀងទុកខាងក្រោយបទនាមនាមនោះ ។

**-សមណោ គោតមោ សក្យបុត្តោ សក្យកុលា បព្វជិតោ ។**

**-វិសាខាបិ មហាឧបាសិកា និពទ្ធំ ទិវសស្ស ទ្វេ វារេ... ។**

**- ទិដ្ឋោ ខោ មេ មហាលិ សក្កោ ទេវានមិន្ទោតិ ។**

**- អថ មហានាមោ សក្កោ អនុរុទ្ធំ ឧបសង្កមិត្វា ។**

៣. បទនាមនាមច្រើនបទ ត្រូវប្រកបវិសេសនៈ ឲ្យមានលិង្គ វចនៈ វិភត្តិស្មើគ្នានឹងនាមដែលជិតបំផុត ។

**- សីលវតី ភិក្ខុនី វា ភិក្ខុ ។ សីលវា បុរិសោ វា ឥត្ថី វា... "កេសា លោមា នខា ទន្តា តចោ សោភណោតិ" គណ្ហាតិ ។**

**- តេនហិ ឆ បញ្ហេ ចត្តារិ តីណិ ទ្វេ ឯកំ សំវច្ឆរំ... ។**

- **តេសុ ឯកេកស្ស ឯកេកា សលាកយាគុ សលាកភត្តំ បក្ខិកភត្តំ  ឧបោសថិកភត្តំ អាគន្តុកភត្តំ វស្សាវាសិកំ**... ។

៤. ក្នុងប្រយោគគួរមានវិសេសនៈ ច្រើនយ៉ាងឲ្យរៀងតាមលំដាប់ គឺ : អនិយម, និយម, គុណនាម , សំខ្យាគុណ , នាម , ឧទាហរណ៍

- **យេ បនិមេ អវសេសា បញ្ចវីសតិ ជនា**... ។

- **យេ ចត្តារោ យោគា មហាជនំ វដ្ដេ ឱសីទាបេន្តិ** ។

- **ឯតេ តេ ភិក្ខវេ ឧភោ អន្តេ អនុបគម្ម មជ្ឈិមា បដិបទា** ។

- **កតមេ តេ ភន្តេ ភណ្ឌាគារកា កោសម្ពិកា ភិក្ខូ** ។

៥. វិសេសនៈដែលសម្រេចមកពី **អន្ត**, **មាន**, **ត**-បច្ច័យ ដែលមិនមែន បឋមាវិភត្តិ រៀងទុកមុខឬក្រោយនាមបាន

- **បសន្នេន ហិ មនេន កតំ កម្មំ ទេវលោកំ មនុស្សលោកំ គច្ឆន្តំ បុគ្គលំ ឆាយាវ ន វិជហតិ** ។

- **តេន នីហរិត្វា ឧស្សិតំ ភាសាវំ ឱស្វា**... ។

- **អថេកទិវសំ មហាបាលោ អរិយសាវកេ គន្ធមាលាទិហត្ថេ វិហារំ គច្ឆន្តេ ទិស្វា**... ។

- **ឥទានាហំ វិហារំ គន្ត្វា ថេរំ តយា ភារិត បណ្ណសាលាយំ និសិន្នកំ ទិស្វា អាគតោម្ហិ ។**

## វិធីរៀនកិរិយាសព្ទ

កិរិយាសព្ទ គឺការធ្វើចលនា មាន ដេក អង្គុយ ឈរ ដើរ ស៊ី ផឹក និយាយ ស្តាប់ គិតជាដើម ហៅថា កិរិយាមាន ២ យ៉ាងគឺ : អនុកិរិយា ១ មហាកិរិយា ១ ។

### ១. អនុកិរិយា

អនុកិរិយា គឺកិរិយារាយរងតូចតាច រៀងទុកក្នុងប្រយោគ មាន ២ យ៉ាងគឺ :

ក. **ត្វាទិកិរិយា** បានដល់កិរិយាប្រកបដោយ **ត្វា, ត្វាន តូន**-បច្ច័យ ។

- **មនុស្សា ថេរំ ទិស្វា "ភន្តេ អម្ហាកំ អយ្យោ កុហន្តិ បុច្ឆិត្វា តំ បវត្តឹ សុត្វា យាគុំ បេសេត្វា សយំ បិណ្ឌបាតំ អាទាយ គន្ត្វា ថេរំ វន្ទិត្វា បាទមូលេ បវដ្ដមានា រោទិត្វា" មយំ ភន្តេ បដិជ្ជគ្គិស្សាម , តុម្ហេ មា ចិន្តយិត្ថាតិ សមស្សាសេត្វា បក្កមឹសុ** (១/១៧) ។

ខ. អព្ពន្តរកិរិយា បានដល់កិរិយាដែលសម្រេចមកពី

**អន្ត**, **មាន**, **ត**-បច្ច័យ ក្នុងកិរិយាកិតកៈ, អព្ភន្តរកិរិយានេះ បើធ្វើព្រមរួមគ្នានឹងកិរិយាធំ សម្ពន្ធចូលកិរិយាធំ ដូចជា :

- **ទេវបុត្តោបិ... ពាហា បគ្គយ្ហ រោទន្តោ អដ្ឋាសិ** (**១/៤០**) ។

- **មហាបុរិសោ... សយំ បច្ចតោ វិលម្ពមានោ អាគច្ឆតិ** (**១/១១៥**) ។

- (**សរទតាបសោ**)... **សត្ថុ សន្តិកេ សារណីយកថំ កថេន្តោ និសីទិ** (**១/១៥៥**) ។

- **មនុស្សា... អសីតិមហាសាវកានំ និសិន្នដ្ឋានំ ឱលោកេន្តា វិចរន្តិ** (**១/២០៣**) ។

## ២. មហាកិរិយា

កិរិយាគ្រប់គ្រងប្រយោគហៅថា កិរិយាធំបានដល់កិរិយាអាខ្យាតទាំងអស់ និងបច្ច័យកិតកៈខ្លះទៀតមាន ៦ ប្រការគឺ :

ក. កិរិយាបទ បានដល់ **សក្កា** ចុះក្នុងវាចកៈ ២ គឺ :

១. កម្មវាចកៈ ដែលមានបទប្រធាន ដូចជា :

- **ន សក្កា សោ អគារមជ្ឈេ វសន្តេន បូរេតុំ** (**១/៨**) ។

- **ពុទ្ធា ច នាម ន សក្កា សថេន អារាធេតុំ** (**១/១២**) ។

- **សេដ្ឋី អត្តនា ។បេ។ តស្ស បាលោតិ នាមំ អកាសិ ។**

ដោយច្រើន អជ្ជត្តនីវិភត្តិ សំរាប់ប្រើក្នុងផ្ទៃរឿង និទាន ឬសេចក្ដីផ្សេងៗ ដែលជាអតីតៈ ។ បរោក្ខា, ហីយត្តនីវិភត្តិ ប្រាប់អតីតកាលដែរ ប៉ុន្តែមានតិចតួច ។

ភវិស្សន្តិវិភត្តិ ប្រើក្នុងរឿងដែលមិនទាន់កើតឡើងក្នុងខណៈនោះដូចជាគំនិត ឬ សន្និដ្ឋានថានឹងកើតមានក្នុងអនាគត ។

**គច្ឆន្តា ច "ទហរសាមណេរា នោ ហត្ថេ ឱលោកេស្សន្តីតិ" តុច្ឆហត្ថា ន គតបុព្វា ។**

**អហំ សត្ថុ សន្តិកេ បព្វជិស្សាមីតិ អាហ ។**

កាលាតិបត្តិវិភត្តិ ប្រើក្នុងការលើកយករឿងចាស់មកពណ៌នាសាជាថ្មី ត្រូវមានប្រយោគ ២ , ប្រយោគទី ១ មាននិបាតបរិកប្ប គឺ **យទិ ចេ** ឬ **សចេ** ដូចភាសាខ្មែរថា :

បើគេខំប្រឹងរៀនពីក្មេង គេនឹងសប្បាយពុំខាន ។

**សោ ចេ យានំ លភិស្សា , សោ អគច្ឆិស្សា** (សេចក្តីស្មានជារឿងមិនពិតប្រាកដទេ) ។ **ស្សា** ច្រើនរស្សៈជា **ស្ស** ។

**សចេ ហិ តុម្ហេ មាទិសស្ស ពុទ្ធស្ស សម្មុខីភាវំ នាគមិស្សថ អហិនកុលានំ វិយ ចេវំ , អច្ឆផន្ទនានំ វិយ , កាកោលូកានំ វិយ ច , កប្បដ្ឋិតិកំ វេរំ ចេវំ អភវិស្ស ។**

## កាលក្នុងកិតកៈ

កាលក្នុងកិតកៈ មាន ២ យ៉ាងគឺបច្ចុប្បន្នកាល និងអតីតកាលបែងចែកតាមបច្ច័យដែលប្រកបនឹងធាតុដូច្នេះ :

**អន្ត** , **មាន** បច្ច័យប្រាប់បច្ចុប្បន្នកាល ។

**ត** , **តវន្តុ** បច្ច័យ ប្រាប់អតីតកាល ។

សព្ទដែលប្រកបដោយបច្ច័យទាំងនោះ មានសេចក្ដីសម្គាល់ដូច្នេះ :

១. **អន្ត, មាន**-បច្ច័យប្រាប់អាការៈ ដែលកំពុងធ្វើ , កំពុងប្រព្រឹត្តទៅ ឬនឹងធ្វើក្នុងពេលខាងមុខដ៏ខ្លីប្រែថា "កាល... កាលនឹង..." ។

- **អហំ ធម្មំ សុណន្តោ បីតិ លភាមិ ។**

- **អនុសន្ធឹ ឃដេត្វា ធម្មំ ទេសេន្តោ ឥមំ គាថមាហ ។**

២. **ត**-បច្ច័យប្រាប់អាការៈដែលធ្វើយូរហើយ ដេកយូរហើយ នៅយូរហើយ ជាដើម ដូចជា :

**មាណវោ "កឹ ឱភាសោ នាមេសោតិ បរិវត្តេត្វា និបន្នោវ" ។**

៣. **ត្វានិ**-បច្ច័យ ប្រាប់អាការៈដែលធ្វើហើយភ្លាមៗ បន្តបន្ទាប់គ្នាតាមលំដាប់ ដូចជា :

**អថេកទិវសំ មហាបាលោ អរិយសាវកេ គន្ធមាលា-ទិហត្ថេ វិហារំ គច្ឆន្តេ ទិស្វា "អយំ មហាជនោ កុហឹ គច្ឆតីតិ" បុច្ឆិត្វា "ធម្មស្សវនាយាតិ" សុត្វា "អហំបិ គមិស្សាមីតិ" គន្ត្វា សត្ថារំ វន្ទិត្វា បរិសបរិយន្តេ និសីទិ ។**

## កាលពិសេស

កាលពិសេស បានដល់កាលដោយឡែកចាកកាលដែលពោលរួចហើយ ដែលប្រើជាគូៗ គ្នាដូចជាសមានកាលកិរិយា ដូច្នេះ **អន្ត**, **មាន**-បច្ច័យជាគូនឹង **ត្វាទិ**-បច្ច័យ, **ត**-បច្ច័យជាគូនឹងកិរិយាអាខ្យាតជាដើម ។ កាលពិសេសនេះមានអត្ថន័យយ៉ាងជ្រាលជ្រៅ ចាត់ជាអត្ថរសរបស់ភាសាជាន់ខ្ពស់ គួរព្យាយាមធ្វើការចូលចិត្តឱ្យដល់ជម្រៅ បើមិនដូច្នេះទេ អាចធ្វើឱ្យខូចសេចក្តី ខូចអត្ថរសរបស់ភាសាបាន ។

១. **អន្ត**, **មាន**-បច្ច័យជាគូនឹង **ត្វាទិ**-បច្ច័យ (**អន្ត**, **មាន** + **ត្វាទិ**... )កាលបើគូប្រធានកំពុងធ្វើកិរិយាណាមួយស្រាប់តែកិរិយាដ៏ទៃទៀត កើតឡើងក្នុងខណៈ នោះដែរ, កិរិយាកំពុងធ្វើលោកឲ្យប្រើ **អន្ត**, **មាន**-បច្ច័យ , ឯកិរិយាមួយទៀតដែលកើតឡើងបន្ទាប់នោះ លោកឱ្យប្រើ **ត្វាទិ**-បច្ច័យ ដូចជា :

**សោ ឯកទិវសំ នហានតិត្ថំ គន្ត្វា នហាត្វា អាគច្ឆន្តោ អន្តរាមគ្គេ សម្បន្នសាខំ ឯកំ វនប្បតឹ ទិស្វា...**

**។បេ។ អាគច្ឆន្តោ** ជាកិរិយាកំពុងធ្វើគឺកំពុងដើរមក ស្រាប់តែខណៈនោះ មានទិស្វាកើតឡើង, **ទិស្វា** ជា **ត្វាទិ**-បច្ច័យឃើញហើយក៏ធ្វើកិរិយាដទៃតទៅ បានសេចក្តីថា : ក្នុងខណៈកំពុងដើរមកបានឃើញ ។ ប្រើកាលខុសដូចជា ។បេ។ **នហាត្វា អាគន្ត្វា... ខនប្បតី ទិស្វា...** ក៏នឹងក្លាយ ទៅជា... ងូតទឹកហើយ ដើរមករួចស្រេចហើយទើបបាន ឃើញ... ដូច្នេះវិញ គឺមកដល់ផ្ទះហើយបានឃើញដើមឈើ ដុះកណ្តាលផ្លូវជាក្រោយ ។

**រាជា បសេនទិកោសលោ ធម្មំ សុណន្តោ តំ សទ្ទំ សុត្វា "បុច្ឆថ នំ, កឹ ករិ តេន ឋិតន្តិ" អាហ** (ខណៈព្រះរាជាកំពុងស្តាប់ធម៌ក៏បានឮសំឡេងនោះរួច ហើយទើបត្រាស់សួរ) បើរៀងថា... **ធម្មំ សុណិត្វា តំ សទ្ទំ សុត្វា...** បានសេចក្តីថា : ទ្រង់ស្តាប់ធម៌រួចស្រេចហើយទើប បានឮសម្លេងនោះ ។

២. **អន្ត**, **មាន**-បច្ច័យមកជាគូនឹងកិរិយាធំ (**អន្ត** , **មាន** + កិរិយាធំ) បើតួប្រធានរបស់ប្រយោគដែលមាន កិរិយា ២ ធ្វើ

រួមគ្នាកើតឡើងព្រមគ្នាឱ្យប្រកបកិរិយាតូចដោយ **អន្ត**, **មាន**-បច្ច័យ កិរិយាធំគ្រប់គ្រងប្រយោគជាបទអាខ្យាត ឬ **ត**-បច្ច័យ ដូចជា :

- **តស្មឹ សមយេ សត្ថា បវត្តិតប្បវរធម្មចក្កោ ជេតវនមហាវិហារេ វិហរតិ មហាជនំ សគ្គមគ្គេ ច មោក្ខមគ្គេ ច បតិដ្ឋាបិយមានោ** ។

- **វិសាខា សសុរំ វីជមានា ឋិតា តំ ថេរំ ទិស្វា អបគន្ត្វា អដ្ឋាសិ** ។

៣. **ត្វាទិ**-បច្ច័យ មកជាគូនឹង **អន្ត**, **មាន** ឬកិរិយាអាខ្យាតក្នុងករណីតួប្រធានមានកិរិយា ២ ធ្វើព្រមគ្នាកិរិយាមួយធ្វើស្រេចហើយប្រកប **ត្វា**-បច្ច័យ រៀងទុកខាងដើមកិរិយាមួយទៀត ធ្វើមិនទាន់ស្រេច ឬស្រេចហើយដូចគ្នា ប្រកប **អន្ត**, **មាន**, ឬកិរិយាអាខ្យាតហៅតាមសម្ពន្ធថា សមានកាលកិរិយា ដូចជា :

**ឯកោ បច្ចេកពុទ្ធោ ឈានំ សមាបជ្ជិត្វា និសីទិ** (អង្គុយចូលឈាន) មិនមែនចូលឈានហើយ ទើបអង្គុយទេ ។

**អម្ហ តវ សស្សុសសុរសាមិកានំ អគុណំ ទិស្វា ពហិ តស្មឹ តស្មឹ គេហេ ឋត្វា មា ភថេសិ** (កុំឈរ និយាយ) ។

**អថ មំ វញ្ញា ទិន្នបរិហារេន តថេវ ឧគ្ឃោសាបេត្វា ទិចរន្តំ មុនចិ រាជា បក្កោសាបេត្វា ។បេ។** (ការឃោសនាជាមួយកាលត្រេចទៅ ធ្វើព្រមគ្នាជា សមានកាល) ។

៩. **ត**-បច្ច័យ មកជាគូនឹងវត្តមានាវិភត្តិ (**តិ**-វត្តមានា **ត**-បច្ច័យ ប្រាប់រឿងអតីត: វត្តមានាប្រាប់រឿងបច្ចុប្បន្នទាំងពីរមកជាគូគ្នា) ។ បានសេក្តីថា : ជារឿងពិតយ៉ាងនេះបានកើតស្រេចហើយនឹងកំពុងធ្វើកិច្ចរឿងអតីត: វត្តមានាប្រាប់រឿងបច្ចុប្បន្នទាំងពីរមកជាគូគ្នា ។ បានសេចក្តីថា : ជារឿងពិតយ៉ាងនេះបានកើតស្រេចហើយ នឹងកំពុងប្រព្រឹត្តទៅក្នុង ខណៈនោះផង ដូចជា ភាសាខ្មែរថា ខណៈនេះអន្តរាយកើតឡើងហើយ ក្នុងស្រុកនោះ = **ឥទានិ អន្តរាយោ តស្មឹ គាមេ ឧប្បន្នោ ហោតិ** (អ្នកនិយាយបំណងថា វេលា និយាយនោះអន្តរាយកើតយូរហើយ នឹងកំពុងប្រព្រឹត្តទៅ មិនទាន់អស់) ។

**តន្តេ អហំ បុព្វេ សាមណេរោ , ឥទានិ បនម្ហិ គិហី**

**ជាតោ**, **បព្វជន្តោបិចាហំ ន សក្ខាយ បព្វជិតោ មគ្គបរិបន្ថកយេន បព្វជិតោ ។បេ។** (ការសឹកជាគ្រហស្ថកើតមានរួចហើយ **អម្ហិ** ប្រាប់ថាការត្រឡប់ជាគ្រហស្ថ កំពុងតាំងនៅ, **បព្វជិតោ** លោកមិនដាក់ **អម្ហិ** ចូលមកទេ ព្រោះការបួសកន្លងផុតទៅហើយ មិនបានគង់នៅក្នុងពេលនោះទេ ) ។

**កុតោ អាគតោសិ ។ ពុទ្ធំ សរណំ គតោស្មិ ។**

៥. **ត**-បច្ច័យ រួមជាគូនឹងភវិស្សន្តិវិភត្តិ (**ត** + **ភវិស្សន្តិ**) **ត**-បច្ច័យ ប្រាប់ដល់រឿងដែលមានមកយូរហើយ, **ភវិស្សន្តិ** ប្រាប់ដល់អនាគត ដែលមិនពិត ដូចជា :

**អយំ មហោសទ្ធាយ ទេវកាយ បរិគ្គហិតោ ភវិស្សន្តិ** (**បរិគ្គហិតោ** ប្រាប់ថាចូលនៅយូរហើយ, **ភវិស្សន្តិ** ប្រាប់ដល់ការគ្មេរគ្មាន់ថា មិនប្រាកដក្នុងចិត្ត) បើរៀងថា **តយាបិ ភោចិ និទ្ទោសោ បុរិមភវេ អកុដ្ឋោ ភវិស្សន្តិ បហដោ ភវិស្សន្តិ** ។

**អជ្ជ អម្ហាកំ រាជភាវោ តុម្ហេហិ ញាតោ ភវិស្សន្តិ ។**

## ៥. វាចកៈ

វាចកៈជាគោលសំខាន់ ក្នុងការរៀបរៀងប្រយោគ ឲ្យមានអត្ថន័យត្រឹមត្រូវច្បាស់លាស់ បើប្រកបសព្ទខុស វាចកៈ ឬ ប្រើវាចកៈខុសហើយ នឹងធ្វើអត្ថន័យខុសវត្ថុបំណង ដូចជាភាសាខ្មែរថា គេធ្វើការ រៀងជាបាលីថា **សោ កម្មន្តំ ករោតិ** តែបើប្រកបសព្ទខុសទៅជា **សោ កម្មន្តំ ករោ** ឬ **តំ កម្មន្តោ ករោ** ឬក៏ **តំ កម្មន្តោ ករោតិ** ប្រើខុសវាចកៈ ស្តាប់មិនបាន ។ **សោ** ជាប្រធានក្នុងកត្តុវាចកៈ **ករោ** ជាកិរិយាកម្មវាចកៈ ព្រោះជាសកម្មធាតុ បទប្រធានគួរតែ **កម្មន្តោ** អ្នកធ្វើត្រូវតែតតិយាវិភត្តិត្រូវរៀងជា **តេន កម្មន្តោ ករោ** ទើបជាប្រយោគកម្មវាចកៈ ឬជា **សោ កម្មំ ករេយ្យ** ប្រយោគកត្តុវាចកៈក៏បាន ។

បើយើងបានជួបភាសាខ្មែរហើយ សូមពិចារណាថា :

"**ឯទំ សុណឹ** ឬ **ឯទម្មេ សុតំ**" "បុណ្យដែលខ្ញុំធ្វើហើយគួរតែលោកម្ចាស់អនុមោទនា = **មយា កតំ បុញ្ញំ សាមិនា អនុមោទិតព្វំ**" ជាវាចកៈអ្វី ? គួរនិយាយ ចំពោះព្រះពុទ្ធឬទេ ? ហេតុអ្វីក៏ឲ្យព្រះពុទ្ធអនុមោទនាយក បុណ្យរបស់យើង ។

មានគោលកំណត់ឲ្យប្រើវាចកៈ ដូចតទៅ ៖

១. **កត្តុវាចកៈ** "កិរិយាសព្ទប្រាប់ដល់កត្តា" ក្នុងប្រយោគ ដែលមានកិរិយាសម្ដែងអាការៈ របស់អ្នកធ្វើជាគោលសំខាន់ ដូចជា **សូទោ ឱទនំ បចតិ** (កិរិយាបញ្ជាក់ដល់អ្នកធ្វើ គឺ **សូទោ**) ។ **ពុទ្ធំ សរណំ គច្ឆាមិ** (កិរិយាប្រាប់ដល់អ្នកធ្វើ គឺ **អហំ**) ជាដើមឲ្យធ្វើជាប្រធានរបស់កិរិយា ។

២. **កម្មវាចកៈ** "កិរិយាសព្ទប្រាប់ដល់អំពើដែលគេត្រូវធ្វើក្នុងប្រយោគនេះ កិរិយាជាសកម្មធាតុបញ្ជាក់ប្រាប់ដល់តួកម្ម (វត្ថុដែលគេត្រូវធ្វើ) ឲ្យឡើងជាប្រធានដូចជា ៖

- **អយំ ធម្មទេសនា ភន្តេ ភាសិតា** ។
- **តាត មយា សត្ថុ ធម្មទេសនា សុតា** ។
- **ឥធានេវេកោ គីតសទ្ទោ សូយិត្ថ** ។

ប្រយោគទាំងបីនេះបញ្ជាក់ដល់ **ទេសនា** និង **សទ្ទោ** ឲ្យឡើងជាប្រធានរបស់កិរិយា តែបើត្រឡប់ជាកត្តុវាចកៈ ថា ៖

- **ឥមំ ធម្មទេសនំ ភន្តេ ភាសតិ ៕**
- **តាត អហំ សត្ថុ ធម្មទេសនំ សុណឹ ៕**
- **ឥធានេវេកំ គីតសទ្ទំ អស្សុណិម្ហា ៕**

ប្រយោគទាំងបីនេះប្រាប់ដល់កត្តាគឺ អ្នកសម្ដែងអ្នកស្ដាប់ឲ្យឡើងជាប្រធានវិញ ។

ម៉្យាងទៀតមានប្រយោគ ដែលបញ្ជាក់ដល់វត្ថុដែលគេត្រូវធ្វើជាកម្មវាចកៈ តែត្រឡប់តែងជាកត្តុវាចកៈទៅវិញ ហៅថា ប្រយោគកត្តុក្រៅកម្មក្នុង, ព្រោះត្រូវការបញ្ជាក់ ដល់វត្ថុដែលបានកើតឡើងហើយ មិនទាន់សាបសូន្យទៅទេកំពុងតាំងនៅឡើយដូចជា :

- **រាជា នាគរេហិ មានិតោ ហោតិ ។**

- **ឥទំ សិក្ខាបទំ ភគវតា ភិក្ខូនំ បញ្ញត្តំ ហោតិ ។**

៣.**ភាវវាចកៈ** (កិរិយាសព្ទប្រាប់ភាវៈមាន , ជា) មិនបានប្រាប់ដល់កត្តា ឬកម្មឡើយ ជាកិរិយាអកម្មធាតុសម្ដែងអាការៈរបស់អនភិហិតកត្តា បើជាអាខ្យាតប្រកបវត្តមានាវិភត្តិ **តេ-អត្តនោបទ** ប៉ុណ្ណោះ ។

បើជាកិតកៈ ប្រើនបុំសកលិង្គ បឋមាវិភត្តិ ឯកវចនៈតែម៉្យាងដូចជា :

- **តេន ភូយតេ ។**

- ( **អយ្យេន** ) **ទិវា ន និទ្ទាយិតព្វំ ។**

- ( **អយ្យេន** ) **អក្កុសីតេន តវចិតព្វំ អារទ្ធវិរិយេន ។**

- **យេ ន ទេន្តិ, តេសំ ន ទាតព្វំ ។**

- **សុខំ តុញ្ជិតព្វំ ។**

៩. **ហេតុកត្តុវាចកៈ** (កិរិយាសព្ទប្រាប់អ្នកធ្វើឲ្យជាហេតុ) ប្រយោគនេះកិរិយាសព្ទប្រាប់អ្នកប្រើគេអោយឡើងជាប្រធាន, មិនបានដាក់បញ្ចូលតួកម្ម ឬការិតកម្មក្នុង ប្រយោគក៏មានខ្លះដូចជា :

- **សោ សត្ថុ ទានំ ទត្វា តុម្ហាកំ បាបេស្សតិ ។**

៥. **ហេតុកម្មវាចកៈ** កិរិយាសព្ទប្រាប់តួកម្មដែលត្រូវគេប្រើឲ្យអ្នកដទៃធ្វើ ជាបទប្រធានដូចជា :

- **អយំ ថូបោ បតិដ្ឋាបិតោ ។**

- **សុនន្ទាយ បោក្ខរណី ការិតា ។**

- **មយា តស្ស បណ្ណសាលា ឈាបិតា ។**

មុននឹងតែងប្រយោគជាវាចកៈណា ត្រូវគិតសេចក្តីជាភាសាខ្មែរ ឲ្យចូលចិត្តជាក់ច្បាស់ថា ប្រយោគនោះគេបញ្ជាក់អ្នកធ្វើ ឬតួកម្មជាដើម ហើយតែងប្រយោគជាវាចកៈ នោះៗទៅ ឲ្យត្រឹមត្រូវតាមវេយ្យាករណ៍ ដូចបានពោលមករួចហើយ ។

## ៦. **បច្ច័យ**

បច្ច័យអាខ្យាត ជាគ្រឿងសំគាល់វាចកៈទាំង ៥ ដូច្នេះ

បច្ច័យ ១៥ ប្រចាំពួកធាតុ និង **ខ**, **ឆ**, **ស**, **អាយ**, **ឦយ**, **អាល**, **អារ**, **អល** សម្រាប់សំគាល់កត្តុវាចកៈ ។

**យ**-បច្ច័យ សម្រាប់សម្គាល់កម្មវាចកៈ និងភាវវាចកៈ ។

**ណេ**, **ណយ**, **ណាបេ**, **ណាបយ**-បច្ច័យ សំគាល់ ហេតុកត្តុវាចកៈ ។

**ណាបេ** + **ឥ** + **យ**-បច្ច័យសំគាល់ហេតុកម្មវាចកៈ ។

បច្ច័យកិរិយាកិតកៈ សម្រាប់សំគាល់វាចកៈផង ប្រាប់កាលផង មានវិធីបំបែកតាមវិភត្តិនាម ត្រូវមានលិង្គ វចនៈ ដូចនាមនាមផងទៀត ។

**អន្ត** , **តវន្តុ** , **តាវី** សំគាល់កត្តុវាចកៈ និងហេតុកត្តុ-វាចកៈ ។

**តព្វ** , **អនីយ** សំគាល់កម្មវាចកៈ ភាវវាចកៈ ហេតុកម្ម-វាចកៈ ។

**មាន** , **ត** , **ត្វាទិ**-បច្ច័យសំគាល់បាន ៥ វាចកៈ ។

ហេតុកត្តុវាចកៈ និងហេតុកម្មវាចកៈ អាចចុះបច្ច័យប្រចាំ ពួកធាតុផង ការិតបច្ច័យផង ដូចជា : **ឧគ្គណ្ហាបេន្តោ** , **ឧគ្គណ្ហាបិយមានោ** , **ការិតោ** , **ការាបិតោ** ។

សូមចាំទុកថាបើប្រើបច្ច័យខុសធ្វើឱ្យខូចវាចកៈ បើវាចកៈខុសហើយក៏ធ្វើឱ្យប្រយោគខុសដែរ ។

ដូចជា **ករោតិ** , **ការេតិ** , **ករិយតេ** , **ការាបិយតេ** ជាដើម យើងចាំបាន ថា **ឱ-ណោ-យ-ណាបេ** + **ឥ** + **យ**-បច្ច័យចុះក្នុងវាចកៈអ្វី ? សព្ទអ្វីជាប្រធាន ? វត្តមានាវិភត្តិ ប្រាប់កាលអ្វី ? បើស្គាល់វាចកៈហើយនឹងបំពេញឱ្យជា ប្រយោគកត្តុ.កម្ម. គ្រប់បរិបូណ៌បានត្រូវមានបទអ្វីទៀត, ត្រឹមត្រូវតាមផ្លូវសម្ពន្ធឬទេ ។

## ៧. សម្ពន្ធ

ក្នុងការរៀងសព្ទចូលក្នុងប្រយោគ គេមិនសូវនឹកដល់គោលសម្ពន្ធទេ ដោយគិតថាមិនជាការសំខាន់ ។ ដើម្បីរៀបរៀងប្រយោគភាសាបាលីឱ្យបានល្អ គួរចៀសវាងកំហុស ៣ យ៉ាងគឺ កំហុសសព្ទ ១ កំហុសសម្ពន្ធ ១ កំហុសប្រយោគ ១ ។

កំហុសសព្ទ : សរសេរខុសដូចជា **ឥទ្វា** ជា **ឥទំ**, **សុចរិត** ជា **សុច្ចរិត**, **ទុក្ខត** ជា **ទុគត**, **វីរិយ** ជា **វិរិយ**, **សេដ្ឋិបុត្ត** ជា **សេដ្ឋីបុត្ត**, ជាដើមក្តី ប្រើលិង្គខុសដូចជា **សា កម្មន្តំ ករោន្តា**, **សោ ឥត្ថំ ភុញ្ជន្តី** ជាដើមក្តី, ប្រើវចនៈខុសដូចជា **បុរិសោ គាមំ គច្ឆន្តិ** ជាដើមក្តី, ប្រើសព្ទខុសអត្ថន័យដូចជាភាសាខ្មែរថា "ផឹកទឹក, គោ ស៊ីស្មៅ, គ្រែនៅក្នុងបន្ទប់" តែងថា "**ឧទកំ ភុញ្ជតិ**, **គោណោ តិណំ ភុញ្ជតិ**, **មញ្ចោ គព្ភេ វសតិ**" ជាដើមក្តី ហៅថា ខុសសព្ទ ។ **ឧទកំ បិវតិ**, **តិណំ ខាទតិ**, **គព្ភេ អត្ថិ** ។

កំហុសសម្ពន្ធដូចជាភាសាខ្មែរថា "សត្វស្លាបនៅលើដើមឈើ, ខ្ញុំទៅវត្ត" "**សកុណោ រុក្ខស្ស ហោតិ**, **អហំ វិហារេ គមិស្សាមិ**" ក្តី រៀងសព្ទខុសទីកន្លែង "ព្រះថេរនាំភិក្ខុទាំងឡាយទៅក្នុងទីនោះហើយគិតថា..." តែងថា "**ថេរោ ភិក្ខូ អាទាយ គន្ត្វា តត្ថ ចិន្តេសិ ។បេ។** ក្តី, កូនសេដ្ឋីបួននាក់ = **ចតុន្នំ សេដ្ឋិនោ បុត្តោ** (ខុសត្រង់ណា សូមកែតម្រូវ) កូនបួននាក់ ឬសេដ្ឋីបួននាក់, "បួន" ជាវិសេសនៈរបស់បទណា ត្រូវមាន

លិង្គ វចនៈ វិភត្តិ ស្មើគ្នានឹងបទនោះ ហេតុនេះទើបឈ្មោះថា ខុសវិធីសម្ពន្ធ ។

កំហុសប្រយោគៈ គឺប្រយោគដែលមានកំហុសសព្ទ និងកំហុសសម្ពន្ធក្តី ប្រើវាចកៈខុស ដូចជា **អាគតោ**, **គច្ឆតិ**, **បព្វជិតព្វោ** មិនមានប្រធានដូច្នេះក្តីរៀងសេចក្តីលេខក្រៅ, លេខក្នុងច្របូកច្របល់គ្នាក្តី ហៅថា ខុសប្រយោគ ។

**អាគតោ** និង **គច្ឆតិ** ជាកត្តុវាចកៈ តែមិនមានប្រធានត្រូវសម្ពន្ធដូចម្តេច ? **បព្វជិតព្វោ** ជាអកម្មធាតុមិនអាច ប្រើកម្មវាចកៈបានទេ , **តព្វ**-បច្ច័យប្រើជាកត្តុវាចកៈមិនបាន ដូច្នេះ **បព្វជិតព្វោ** ឈ្មោះវាចកៈអ្វីទៅ ។

សូមសង្កេតប្រយោគដូចតទៅនេះ :

-**តន្តេ អហំ បុព្វេ សាមណេរោ** ។ ខ្វះកិរិយា ។

-**តន្តេ បុព្វេ សាមណេរោ អហោសិ** ។ ខ្វះប្រធាន ។

-**ឥទានិ បនម្ហិ គិហី ជាតោ** ។ ខ្វះប្រធាន ។

-**ឥទានិ បន គិហី ជាតោម្ហិ** ។ ខ្វះប្រធាន ។

-**ឥមិនា ភារណេនាហំ ឥមិនា អតិសបិតោ** ។

- **ឥមិនា ភារណោន ឥមិនា អភិសបិតោម្ហិ** ។ ខ្ញុំ
ប្រធាន ។

ប្រយោគទាំងនេះ ត្រឹមត្រូវតាមវិធីសម្ពន្ធ និងអត្ថន័យ ព្រោះកិរិយាអាខ្យាតបង្គាប់ប្រធានបានគ្រប់គ្រាន់ហើយ ។

ជាដំបូង យើងត្រូវពិចារណា អត្ថន័យរបស់ប្រយោគ ដូចជា "កូនសេដ្ឋីបួននាក់" តើសេដ្ឋីបួននាក់មានកូនមួយ ឬ កូនបួននាក់របស់សេដ្ឋីម្នាក់ ? **ចតុន្នំ** ជា ច. ឆ. ពហុ. **សេដ្ឋីនោ** ជា ច. ឆ. ឯក. ឬ ប. ទុ. អា. ពហុ. **បុត្តោ** ប. ឯក. ។ បើកូនរបស់សេដ្ឋីទាំងឡាយបួននាក់ = **ចតុន្នំ សេដ្ឋីនំ បុត្តោ** ។ កូនទាំងឡាយបួននាក់របស់សេដ្ឋី = **ចត្តារោ សេដ្ឋីនោ បុត្តា** ។ ប្រយោគទាំងពីរនេះជាលិង្គត្ថៈ ដូចគ្នា តើប្រយោគណាមួយត្រឹមត្រូវ ? ។

១. សម្ពន្ធ **ចតុន្នំ** វិសេសនៈរបស់ **សេដ្ឋីនំ**ៗ សាមិ-សម្ពន្ធក្នុង **បុត្តោ**ៗ លិង្គត្ថៈ ។ ត្រូវតាមផ្លូវសម្ពន្ធ តែខុសអត្ថន័យ ។

២. សម្ពន្ធ **ចត្តារោ** វិសេសនៈរបស់ **បុត្តា** , **សេដ្ឋិនោ**

សាមិសម្ពន្ធក្នុង **បុត្តា**ៗ លិង្គត្ថៈ ត្រូវទាំងសម្ពន្ធទាំងអត្ថន័យ ។

មុននឹងតែងប្រយោគបាលី ត្រូវគិតសេចក្ដីខ្មែរឲ្យបានច្បាស់លាស់សិនទើបរិះរកសព្ទបាលី វិភត្តិ កាល ជាដើម រៀបរៀងជាប្រយោគ រួចហើយសម្ពន្ធមើល តើត្រឹមត្រូវតាមវេយ្យករណ៍ និងវិធីសម្ពន្ធ ឬទេ ។

## លំហាត់

សូមរៀបរៀងប្រយោគកត្តុវាចកៈ ១ កម្មវាចកៈ ១ ហេតុកត្តុវាចកៈ ១, ហេតុកម្មវាចកៈ ១ ដោយសព្ទ : **បិតុ**, **បុត្ត**, **អក្ខរ**, **លិខ**, ហើយសម្ពន្ធ ។

## ភាសាខ្មែរ

១. កត្តុ. កូនរបស់បិតាសរសេរនូវអក្សរទ. ។

២. កម្ម. អក្សរទ. គឺកូនរបស់បិតាតែងតែសរសេរ ។

៣. ហេតុកត្តុ. បិតាញុំាងកូនឲ្យសរសេរនូវ អក្សរទ. ។

៤. ហេតុកម្ម. អក្សរទ. គឺបិតាញុំាងកូនឲ្យសរសេរ ។

## ភាសាបាលី

១. កត្តុ. ..........................................................។

២. កម្ម. ......................................................។

៣. ហេតុកត្តុ. .............................................។

៤. ហេតុកម្ម. .......................................។

## សម្ពន្ធ

១. កត្តុ. ......................................................។

២. កម្ម. ......................................................។

៣. ហេតុកត្តុ. .............................................។

៤. ហេតុកម្ម. .....................................។

## លំហាត់

### ១. ខេមរបរិវត្តន៍

**សត្តស្ស នាថោ ពុទ្ធោ** ។

**សត្តស្ស** សាមិសម្ពន្ធក្នុង **នាថោ**ៗ វិសេសនៈរបស់ **ពុទ្ធោ**ៗ លិង្គត្ថៈ ។

- **សត្តានំ នាថស្ស ពុទ្ធស្ស អានុភាវោ** ។

**សត្តានំ** សាមិសម្ពន្ធក្នុង **នាថស្ស**ៗ វិសេសនៈរបស់ **ពុទ្ធស្ស**ៗ សាមិសម្ពន្ធក្នុង **អានុភាវោ**ៗ លិង្គត្ថៈ ។

- **លោកេ អគ្គោ ធម្មោ បសាទោ** ។

- **លោកេ** អាធារក្នុង **អគ្គោ**ៗ វិសេសនៈរបស់ **ធម្មោ**ៗ ភិន្នាធារក្នុង **បសាទោ**ៗ លិង្គត្ថៈ ។

- **តបា អាទិច្ចស្ស អាភា** ។

**តបា** វិសេសនៈរបស់ **អាភា**, **អាទិច្ចស្ស** សាមិសម្ពន្ធក្នុង **អាភា**ៗ លិង្គត្ថៈ ។

- **កណ្ហានំ គោណានំ តចោ** ។

**កណ្ហានំ** វិសេសនៈរបស់ **គោណានំ**ៗ សាមិសម្ពន្ធក្នុង **តចោ**ៗ លិង្គត្ថៈ ។

- **ពុទ្ធោ លោកេ ឧប្បន្នោ** ។

**ពុទ្ធោ** សយកត្តាក្នុង **ឧប្បន្នោ**, **លោកេ** វេសយិកា-ធារក្នុង **ឧប្បន្នោ**ៗ កិតបទ-កត្តុវាចកៈ ។

- **ធម្មោ សប្បុរិសានំ សន្តានេ ឋិតោ** ។

**ធម្មោ** សយកត្តាក្នុង **ឋិតោ** , **សប្បុរិសានំ** សាមិសម្ពន្ធក្នុង **សន្តានេ**ៗ ព្យាបិកាធារក្នុង **ឋិតោ**ៗ កិតបទ-កត្តុវាចកៈ ។

- **ភគវា អនុបុព្វេន រាជគហំ បត្តោ** ។

**ភគវា** សយកត្តាក្នុង **បត្តោ** , **អនុបុព្វេន** គតិយា-វិសេសនៈក្នុង **បត្តោ**, **រាជគហំ** សម្បាបុណិយកម្មក្នុង **បត្តោ**ៗ កិតបទ-កត្តុវាចកៈ ។

- **រាជា មហន្តេន បរិវារេន នគរា និក្ខន្តោ** ។

**រាជា** សយកត្តាក្នុង **និក្ខន្តោ**, **មហន្តេន** វិសេសនៈរបស់ **បរិវារេន**ៗករណៈក្នុង **និក្ខន្តោ** , **នគរា** អបាទានក្នុង **និក្ខន្តោ**ៗ កិតបទ-កត្តុវាចកៈ ។

- **ព្រាហ្មណា នគរំ បិណ្ឌាយ បវិដ្ឋា** ។

**ព្រាហ្មណា** សយកត្តាក្នុង **បវិដ្ឋា** , **នគរំ** សម្បាបុ-ណិយកម្មក្នុង **បវិដ្ឋា**, **បិណ្ឌាយ** សម្បទានៈក្នុង **បវិដ្ឋា**ៗ កិតបទ-កត្តុវាចកៈ ។

## ២. បាលិបរិវត្តន៍

**សង្ឃោ** រីពួក **សាវកានំ** នៃសាវ័កទ. **មហន្តោ** ធំ ។

**មហន្តោ** វិសេសនៈរបស់ **សង្ឃោ** , **សាវកានំ** សម្ពហសម្ពន្ធក្នុង **សង្ឃោ**ៗ លិង្គត្ថៈ ។

**វិបាកោ** រីផល **ធម្មស្ស** នៃធម៌ **សុន្ទរស្ស** ល្អ ។

**សុន្ទរស្ស** វិសេសនៈរបស់ **ធម្មស្ស**ៗ សាមិសម្ពន្ធក្នុង **វិបាកោ**ៗ លិង្គត្ថៈ ។

**មតិ** រីសេចក្ដីដឹង **អាចរិយស្ស**ៗ របស់អាចារ្យ **កុសល-ស្ស** ប៉ិនប្រសប់ ។

**កុសលស្ស** វិសេសនៈរបស់ **អាចរិយស្ស**ៗ សាមិ-សម្ពន្ធក្នុង **មតិ**ៗ លិង្គត្ថៈ ។

**បុត្តោ** រីកូន **កុលស្ស** នៃត្រកូល **អឌ្ឍស្ស** ស្ដុកស្ដម្ភ ។

**អឌ្ឍស្ស** វិសេសនៈរបស់ **កុលស្ស**ៗ សាមិសម្ពន្ធក្នុង **បុត្តោ**ៗ លិង្គត្ថៈ ។

**ជនា** រីជនទ. **សាលាយំ** ក្នុងសាលា **មហតិយំ** ធំ ។

**មហតិយំ** វិសេសនៈរបស់ **សាលាយំ**ៗ ភិន្នាធារក្នុង **ជនា**ៗ លិង្គត្ថៈ ។

**ភិក្ខូ** រីភិក្ខុទ. **បវិដ្ឋា** ចូលទៅហើយ **គាមំ** កាន់ស្រុក **បិណ្ឌាយ** ដើម្បីបិណ្ឌបាត ។

**ភិក្ខូ** សយកត្តាក្នុង **បវិដ្ឋា**ៗ កិតបទ-កត្តុវាចកៈ **គាមំ** សម្បាបុណិយកម្មក្នុង **បវិដ្ឋា** , **បិណ្ឌាយ** សម្បទានៈក្នុង

**បវិដ្ឋា** ។

**ហត្ថី** រីដំរី **ឋិតោ** ឈរនៅហើយ **សាលាយំ** ក្នុងរោង **ជិណ្ណាយ** គ្រាំគ្រា ។

**ហត្ថី** សយកត្តាក្នុង **ឋិតោ**ៗ កិតបទ-កត្តុវាចកៈ **ជិណ្ណាយ** វិសេសនៈរបស់ **សាលាយំ**ៗ វេសយិកាធារក្នុង **ឋិតោ** ។

**បុរិសោ** រីបុរស **ចណ្ឌោ** កាច **ភិន្នោ** បែកហើយ **ញាតីហិ** ចាកញាតិទ. **អត្តនោ** របស់ខ្លួន ។

**បុរិសោ** សយកត្តាក្នុង **ភិន្នោ**ៗ កិតបទ-កត្តុវាចកៈ **ចណ្ឌោ** វិសេសនៈរបស់ **បុរិសោ**, **អត្តនោ** សាមិសម្ពន្ធក្នុង **ញាតីហិ**ៗ អបាទានៈក្នុង **ភិន្នោ** ។

**តាបសោ** រីតាបស **គតោ** ទៅហើយ **វនំ** កាន់ព្រៃ **អត្ថាយ** ដើម្បីប្រយោជន៍ **ផលានំ** ដល់ផ្លែឈើទ. ។

**តាបសោ** សយកត្តាក្នុង **គតោ**ៗ កតិបទ-កត្តុវាចកៈ **ផលានំ** សម្បទានៈក្នុង **អត្ថាយ**ៗ សម្បទានៈក្នុង **គតោ**, **វនំ** សម្បាបុណិយកម្មក្នុង **គតោ** ។

**រាជិនី** រីព្រះរាជិនី **ឋិតា** ប្រថាប់នៅហើយ **មជ្ឈេ** ក្នុងកណ្តាល **នារីនំ** នៃនារីទ. ។

**រាជិនី** សយកត្តាក្នុង **ឋិតា**ៗ កិតបទ-កត្តុវាចក:, **នារីនំ** សាមិសម្ពន្ធក្នុង **មជ្ឈេ**ៗ អាធារក្នុង **ឋិតា** ។

## ៣. ខេមរបរិវត្តន៍

- **សុក្ខា សាខា រុក្ខា បតិតា** ។

**សុក្ខា** វិសេសនៈរបស់ **សាខា**ៗ សយកត្តាក្នុង **បតិតា** , **រុក្ខា** អាបាទានក្នុង **បតិតា**ៗ កិតបទកត្តុវាចក: ។

- **នីលំ ឧប្បលំ ឧទកេ ជាតំ** ។

**នីលំ** វិសេសនៈរបស់ **ឧប្បលំ**ៗ សយកត្តាក្នុង **ជាតំ** , **ឧទកេ** វេសយិកាធារៈក្នុង **ជាតំ**ៗ កិតបទ-កត្តុវាចក: ។

- **កញ្ញា បតិនោ កុលំ គតា** ។

**កញ្ញា** សយកត្តាក្នុង **គតា** , **បតិនោ** សាមិសម្ពន្ធក្នុង **កុលំ**ៗ សម្បាបុណិយកម្មក្នុង **គតា**ៗ កិតបទ-កត្តុវាចក: ។

- **ភិក្ខូ មហន្តេ វិហារេ និសិន្នា**។

**ភិក្ខូ** សយកត្តាក្នុង **និសិន្នា** , **មហន្តេ** វិសេសនៈរបស់

**វិហារេ** វេសយិធារៈក្នុង **និសិន្នា**ៗ កិតបទ-កត្តុវាចកៈ។

- **ជនោ គាមេ ឧច្ចាយ សាលាយំ និបន្នោ**។

**ជនោ** សយកត្តាក្នុង **និបន្នោ** , **គាមេ** សមីបាធារៈ ក្នុង **សាលាយំ** , **ឧច្ចាយ** វិសេសនៈរបស់ **សាលាយំ**ៗ វេសយិកាធារៈក្នុង **និបន្នោ**ៗ កិតបទ-កត្តុវាចកៈ ។

- **ឯកូនសដ្ឋី អរហន្តោ លោកេ ឧប្បន្នា** ។

**ឯកូនសដ្ឋី** វិសេសនៈរបស់ **អរហន្តោ**ៗ សយកត្តាក្នុង **ឧប្បន្នា** , **លោកេ** វេសយិកាធារក្នុង **ឧប្បន្នា**ៗ កិតបទ-កត្តុវាចកៈ ។

- **ចតស្សោ សាខា រុក្ខា គតា** ។

**ចតស្សោ** វិសេសនៈរបស់ **សាខា**ៗ សយកត្តាក្នុង **គតា** , **រុក្ខា** អបាទានៈ ក្នុង **គតា**ៗ កិតបទ-កត្តុវាចកៈ ។

- **ចុទ្ទស បុរិសា ឯកវីសតិយា ឥត្ថីហិ នទិយំ គតា** ។

**ចុទ្ទស** វិសេសនៈរបស់ **បុរិសា**ៗ សយកកត្តាក្នុង **គតា**, **នទិយំ** អាធារក្នុង **គតា**ៗ កិតបទ-កត្តុវាចកៈ **ឯកវីសតិយា** វិសេសនៈរបស់ **ឥត្ថីហិ**ៗករណៈក្នុង **គតា** ។

- **ចតុត្ថាឡីសាយ ព្រាហ្មណានំ ភត្តំ ទារកស្ស បិតរា ទិន្នំ ។**

**ចតុត្ថាឡីសាយ** វិសេសនៈរបស់ **ព្រាហ្មណានំ**ៗ សម្បទានក្នុង **ទិន្នំ** , **ភត្តំ** វុត្តកម្មក្នុង **ទិន្នំ** , **ទារកស្ស** សាមិសម្ពន្ធក្នុង **បិតរា**ៗ អនភិហិតកត្តាក្នុង **ទិន្នំ**ៗ កិតបទ-កម្មវាចកៈ ។

- **ឋានំ រញ្ញា អដ្ឋត្តឹសាយ ជនានំ ទិន្នំ ។**

**ឋានំ** វុត្តកម្មក្នុង **ទិន្នំ** , **រញ្ញា** អនភិហិតកត្តាក្នុង **ទិន្នំ** , **អដ្ឋត្តឹសាយ** វិសេសនៈរបស់ **ជនានំ**ៗ សម្បទានក្នុង **ទិន្នំ**ៗ កិតបទ-កម្មវាចកៈ ។

## ៤. បាលិបរិវត្តន៍

**ភិក្ខូ** វីភិក្ខុទ. **ចត្តារោ** បួនអង្គ **បវិដ្ឋា** ចូលទៅហើយ **គាមំ** កាន់ស្រុក **បិណ្ឌាយ** ដើម្បីបិណ្ឌបាត ។

**ចត្តារោ** វិសេសនៈរបស់ **ភិក្ខូ**ៗ សយកត្តាក្នុង **បវិដ្ឋា**, **គាមំ** សម្បាបុណិកម្មក្នុង **បវិដ្ឋា** , **បិណ្ឌាយ** សម្បទានក្នុង **បវិដ្ឋា**ៗ កិតបទ-កត្តុវាចកៈ ។

**មាសា** រីខែទ. **តយោ** បី **អតិក្កន្តា** កន្លងទៅហើយ។

**តយោ** វិសេសនៈរបស់ **មាសា**ៗ សយកត្តាក្នុង **អតិក្កន្តា**ៗ កិតបទ-កត្តុវាចកៈ ។

**នារិយោ** រីនាងទ. **ឯកូនវីសតិ** ១៩ នាក់ **គតា** ទៅហើយ **នទឹ** កាន់ស្ទឹង **នហានាយ** ដើម្បីងូត ។

**ឯកូនវីសតិ** វិសេសនៈរបស់ **នារិយោ**ៗ សយកត្តាក្នុង **គតា**, **នហានាយ** សម្បទានក្នុង **គតា**, **នទឹ** សម្បាបុ-ណិយកម្មក្នុង **គតា**ៗ កិតបទ-កត្តុវាចកៈ ។

**ចីវរានិ** រីចីវរទ. **ទាយកេហិ** គឺទាយកទ. **ទិន្នានិ** ប្រគេនហើយ **ភិក្ខូនំ** ដល់ភិក្ខុទ. **ចតុប្បញ្ញាសាយ** ៥៤ អង្គ ។

**ចតុប្បញ្ញាសាយ** វិសេសនៈរបស់ **ភិក្ខូនំ**ៗ សម្បទានក្នុង **ទិន្នានិ** , **ចីវរានិ** វុត្តកម្មក្នុង **ទិន្នានិ**, **ទាយកេហិ** អនភិហិតកត្តាក្នុង **ទិន្នានិ**ៗ កិតបទ-កម្មវាចកៈ ។

**អាចរិយោ** រីអាចារ្យ **កុមារានំ** នៃកុមារទ. **តេវីសតិយា** ២៣ នាក់ **បវិដ្ឋោ** ចូលទៅហើយ **គាមំ** កាន់ស្រុក ។

**តេវីសតិយា** វិសេសនៈរបស់ **កុមារានំ**ៗ សាមិ-សម្ពន្ធក្នុង **អាចរិយោ**ៗ សយកត្តាក្នុង **បវិជ្ជោ** , **គាមំ** សម្បា-បុណិយកម្មក្នុង **បវិជ្ជោ**ៗ កិតបទ-កត្តុវាចកៈ ។

**ធនំ** រីទ្រព្យ **រញ្ញោ** របស់ព្រះរាជ **ពហុំ** ច្រើន **សុទ្ធា** រីស្ទួយទ. **នាគរេហិ** គឺអ្នកនគរទ. **ទិន្នា** ថ្វាយហើយ **តស្ស** (**រញ្ញោ**) ដល់ព្រះរាជាអង្គនោះ ។

**ពហុំ** វិសេសនៈរបស់ **ធនំ** , **រញ្ញោ** សាមិសម្ពន្ធក្នុង **ធនំ**ៗ លិង្គត្ថៈ **តស្ស** វិសេសនៈរបស់ (**រញ្ញោ**)ៗ សម្បទានក្នុង **ទិន្នា**, **នាគរេហិ** អនភិហិតកត្តាក្នុង **ទិន្នា** , **សុទ្ធា** វុត្តកម្មក្នុង **ទិន្នា**ៗ កិតបទ-កម្មវាចកៈ ។

**មាតា** រីមាតា **សេដ្ឋិនោ** របស់សេដ្ឋី **បសន្នា** ជ្រះថ្លាហើយ **សាសនេ** ក្នុងព្រះសាសនា **ទានំ** រីទាន **តាយ** (**មាតុយា**) គឺមាតានោះ **ទិន្នំ** ថ្វាយហើយ **សង្ឃស្ស** ដល់សង្ឃ ។

**សេដ្ឋិនោ** សាមិសម្ពន្ធក្នុង **មាតា**ៗ សយកត្តាក្នុង **បសន្នា**, **សាសនេ** ព្យាបិកាធារក្នុង **បសន្នា**ៗ កិតបទ-កត្តុវាចកៈ **តាយ** វិសេសនៈរបស់ (**មាតុយា**)ៗ អនភិហិតកត្តាក្នុង **ទិន្នំ**,

**សង្ឃស្ស** សម្បទានក្នុង **ទិន្នំ** , **ទានំ** វុត្តកម្មក្នុង **ទិន្នំ**ៗ កិតបទ-កម្មវាចក: ។

**ចីវរានិ** រីចីវរទ. **ពហូនិ** ច្រើន **ឧប្បន្នានិ** កើតឡើងហើយ **សង្ឃស្ស** ដល់សង្ឃ , **តានិ** (**ចីវរានិ**) រីចីវរទ. នោះ (**សង្ឃេន** គឺសង្ឃ) **វិភត្តានិ** ចែកហើយ **ភិក្ខូនំ** ដល់ភិក្ខុទ. ។

**ពហូនិ** វិសេសនៈរបស់ **ចីវរានិ**ៗ សយកត្តាក្នុង **ឧប្បន្នានិ** **សង្ឃស្ស** សម្បទានក្នុង **ឧប្បន្នានិ**ៗ កតិបទ-កត្តុវាចក: **តានិ** វិសេសនៈរបស់ (**ចីវរានិ**)ៗ វុត្តកម្មក្នុង **វិភត្តានិ**, (**សង្ឃេន**) អនភិហិតកត្តាក្នុង **វិភត្តានិ** , **ភិក្ខូនំ** សម្បទានក្នុង **វិភត្តានិ**ៗ កិតបទ-កម្មវាចក: ។

**កុលំ** រីត្រកូល **ខត្តិយស្ស** របស់ក្សត្រិយ៍ **ឧត្តមំ** ខ្ពស់, **តំ** (**កុលំ**) រីត្រកូលនោះ **ជនេហិ** គឺជនទ. **មានិតំ** បូជាហើយ ។

**ឧត្តមំ** វិសេសនៈរបស់ (**កុលំ**), **ខត្តិយស្ស** សាមិ-សម្ពន្ធក្នុង **កុលំ**ៗ លិង្គត្ថៈ , **តំ** វិសេសនៈរបស់ (**កុលំ**)ៗ វុត្តកម្មក្នុង **មានិតំ**, **ជនេហិ** អនភិហិតកត្តាក្នុង **មានិតំ**ៗ កិតបទ-កម្មវាចក: ។

**និគ្រោធោ** រីដើមជ្រៃ **មហន្តោ** ធំ **ជាតោ** កើតហើយ **អរញ្ញេ** ក្នុងព្រៃ។ **សកុណា** រីសត្វស្លាបទ. **និលីនា** ពួនហើយ **តស្មឹ** (**និគ្រោធេ**) លើដើមជ្រៃនោះ ។

**មហន្តោ** វិសេសនៈរបស់ **និគ្រោធោ**ៗ សយកត្តាក្នុង **ជាតោ**, **អរញ្ញេ** វេសយិការធារក្នុង **ជាតោ**ៗ កិតបទ-កត្តុវាចកៈ, **សកុណា** សយកត្តាក្នុង**និលីនា** , **តស្មឹ** វិសេសនៈរបស់ (**និគ្រោធេ**)ៗ ឧបសិលេសិកាធារក្នុង **និលីនា**ៗ កិតបទ-កត្តុវាចកៈ ។

## ៥. ខេមរបរិវត្តន៍

- **ចន្ទោ នភេ ឧគ្គតោ** , **សោ មេឃេន បដិច្ឆន្នោ** ។

**ចន្ទោ** សយកត្តាក្នុង **ឧគ្គតោ** , **នភេ** ឧបសិលេសិកា-ធារក្នុង **ឧគ្គតោ**ៗ កិតបទ-កត្តុវាចកៈ, **សោ** វិសេសនៈរបស់ (**ចន្ទោ**)ៗ វុត្តកម្មក្នុង **បដិច្ឆន្នោ**ៗ កិតបទ-កម្មវាចកៈ **មេឃេន** អនភិហិតកត្តាក្នុង **បដិច្ឆន្នោ** ។

- **ឧបាសិកាយោ អាវាសំ គតា** , **ធម្មោ តាហិ សុណិតោ** ។

**ឧបាសិកាយោ** សយកត្តាក្នុង **គតា**, **អាវាសំ** សម្បា-បុណិយកម្មក្នុង **គតា**ៗ កិតបទ-កត្តុវាចកៈ **ធម្មោ** វុត្តកម្មក្នុង **សុណិតោ**, **តាហិ** អនភិហិតកត្តាក្នុង **សុណិតោ**ៗ កិតបទ-កម្មវាចកៈ ។

- **ទេវោ វុដ្ឋោ**, **តស្ស ពិន្ទូនិ ចាដិយំ បរិបុណ្ណានិ** ។

**ទេវោ** សយកត្តាក្នុង **វុដ្ឋោ**ៗ កិតបទ-កត្តុវាចកៈ **តស្ស** សាមិសម្ពន្ធក្នុង **ពិន្ទូនិ**ៗ សយកត្តាក្នុង **បរិបុណ្ណានិ** **ចាដិយំ** បដិច្ឆន្នាធារក្នុង **បរិបុណ្ណានិ**ៗ កិតបទ-កត្តុវាចកៈ ។

**សិស្សា អាចរិយំ ឧបគតា**, **ឱវាទោ តេន តេសំ ទិន្នោ** ។

**សិស្សា** សយកត្តាក្នុង **ឧបគតា**, **អាចរិយំ** អវុត្តកម្មក្នុង **ឧបគតា**ៗ កិតបទ-កត្តុវាចកៈ **ឱវាទោ** វុត្តកម្មក្នុង **ទិន្នោ**, **តេន** អនភិហិតកត្តាក្នុង **ទិន្នោ**, **តេសំ** វិសេសនៈរបស់ (**សិស្សានំ**)ៗ សម្បទានក្នុង **ទិន្នោ**ៗ កិតបទ-កម្មវាចកៈ ។

- **អម្ពស្ស ផលំ សាខាយ បតិតំ**, **តំ ទារកេន គហិតំ** ។

**អម្ពស្ស** សាមិសម្ពន្ធក្នុង **ផលំ**ៗ សយកត្តាក្នុង **បតិតំ**, **សាខាយ** អបាទានក្នុង **បតិតំ**ៗ កិតបទ-កត្តុវាចកៈ **តំ** វុត្តកម្ម

ក្នុង **គហិតំ** , **ទារកេន** អនភិហិតកត្តាក្នុង **គហិតំ**ៗ កិតបទ-កម្មវាចក: ។

- **តវ បុត្តោ មម បុត្តេន ធនំ គតោ** ។

**បុត្តោ** សយកត្តាក្នុង **គតោ**ៗ កិតបទ-កត្តុវាចក: **តវ** សាមិសម្ពន្ធក្នុង **បុត្តោ** , **មម** សាមិសម្ពន្ធក្នុង **បុត្តេន**ៗ សហាត្ថតតិយាក្នុង **គតោ** , **ធនំ** សម្បាបុណិកម្មក្នុង **គតោ** ។

- **ឥមានិ បុច្ឆានិ តវ អាចរិយស្ស មេ មាតរា ឋិន្នានិ** ។

**បុច្ឆានិ** វុត្តកម្មក្នុង **ឋិន្នានិ**ៗ កិតបទ-កម្មវាចក: **ឥមានិ** វិសេសន:របស់ **បុច្ឆានិ**, **តវ** សាមិសម្ពន្ធក្នុង **អាចរិយស្ស**ៗ សម្បទានក្នុង **ឋិន្នានិ** , **មេ** សាមិសម្ពន្ធក្នុង **មាតរា** អនភិ-ហិតកត្តាក្នុង **ឋិន្នានិ** ។

## ៦. បាលិបរិវត្តន៍

អាចារ្យតែងឲ្យនូវឱវាទដល់សិស្សទ. របស់ខ្លួន ។ សិស្សទ. នោះរមែងស្តាប់ ។

**អាចរិយោ** សយកត្តាក្នុង **ទេតិ**ៗ អាខ្យាតបទ-កត្តុវាចក: **អត្តនោ** សាមិសម្ពន្ធក្នុង **សិស្សានំ** , **ឱវាទំ** អវុត្តកម្មក្នុង **ទេតិ**,

**តេ** វិសេសនៈរបស់ (**សិស្សា**)ៗ សយ-កត្តាក្នុង **សុណន្តិ**ៗ អាខ្យាតបទ-កត្តុវាចកៈ។

ទារកទ. តែងសិក្សានូវសិល្បៈរាល់ថ្ងៃ ។ ទារកទ. នោះរមែងដល់នូវ សេចក្តីចំរើនតាមលំដាប់ ។

**ទារកា** សយកត្តាក្នុង **សិក្ខន្តិ**ៗ អាខ្យាតបទ-កត្តុវាចកៈ **ទិវសេ ទិវសេ** កាលត្ថសត្តមីក្នុង **សិក្ខន្តិ** , **សិប្បំ** អវុត្តកម្មក្នុង **សិក្ខន្តិ**, **តេ** វិសេសនៈរបស់ (**ទារកា**)ៗ សយកត្តាក្នុង **បាបុណន្តិ**ៗ អាខ្យាតបទ-កត្តុវាចកៈ **អនុក្កមេន** តតិយាវិសេសនៈក្នុង **បាបុណន្តិ**, **វុឌ្ឍឹ** អវុត្តកម្មក្នុង **បាបុណន្តិ** ។

ពន្លឺនៃបញ្ញា រុងរឿងជាងពន្លឺទាំងឡាយទាំងពួង ។

**បញ្ញាយ** សាមី... **បភា**ៗ សយ... **វិរោចតិ**ៗ អាខ្យា... កត្តុ... **សព្វាហិ** វិសេ... **បភាហិ**ៗ អាបា... **វិរោចតិ** ។

បុគ្គលណាសេពគប់នូវជនពាលទ. បុគ្គលនោះ តែងដល់នូវ សេចក្តីវិនាស ។

**យោ** វិសេ... (**បុគ្គលោ**)ៗ សយ... **សេវតិ**ៗ អាខ្យា... កត្តុ... **ពាលេ** អវុត្ត... **សេវតិ** , **សោ** វិសេ... ( **បុគ្គលោ**)ៗ

សយ... **ធាបុណាតិ**ៗ អាខ្យា... កត្តុ... **ទិនាសំ** អវុត្ត... **ធាបុណាតិ** ។

សប្បុរសទ. តែងធ្វើនូវមេត្តា ក្នុងសត្វទ. ទាំងពួង ។

**សប្បុរិសា** សយ... **ភវេន្តិ**ៗ អាខ្យា... កត្តុ... **សព្វេសុ** វិសេ... **សត្តេសុ**ៗ ព្យាបិកា... **មេត្តំ**ៗ អវុត្ត... **ភវេន្តិ** ។

យើងទាំងឡាយ តែងប្រព្រឹត្តនូវព្រហ្មចរិយៈក្នុងព្រះមានព្រះភាគអង្គនោះ ។

**មយំ** សយ... **ចរាម**ៗ អាខ្យា... កត្តុ... **តស្មឹ** វិសេ..... **ភគវតិ**ៗ ឧបសិលេ... **ចរាម** , **ព្រហ្មចរិយំ**ៗ អវុត្ត... **ចរាម** ។

មាតាតែងប្រៀនប្រដៅកូនរបស់ខ្លួន ។ កូននោះរមែងតាំងនៅក្នុងឱវាទរបស់មាតានោះ ។

**មាតា** សយ... **អនុសាសតិ**ៗ អាខ្យា... កត្តុ... **អត្តនោ** សាមិ... **បុត្តំ**ៗ អវុត្ត... **អនុសាសតិ** ។

**សោ** វិសេ... (**បុត្តោ**)ៗ សយ... **តិដ្ឋតិ**ៗ អាខ្យា... កត្តុ... **តស្សា** វិសេ... (**មាតុយា**)ៗ សាមិ... **ឱវាទេ**ៗ ឧបសិលេ... **តិដ្ឋតិ** ។

លោកទៅកាន់និវេសន៍នៃព្រះរាជាតាមផ្លូវណា ។

**ត្វំ** សយ... **គច្ឆសិ**ៗ អាខ្យា... កត្តុ... **កតរេន** វិសេ... **មគ្គេន**ៗ គតិយាវិ... **គច្ឆសិ** , **រញ្ញោ** សាមិ... **និវេសនំ**ៗ សម្បាបុ... **គច្ឆសិ** ។

លោកទ. តែងនៅក្នុងស្រុកណា ? (យើងទ.) តែងនៅក្នុងទីជិតនៃនគរ ។

**តុម្ហេ** សយ... **វសថ**ៗ អាខ្យា... កត្តុ... **កតរស្មឹ** វិសេ... **គាមេ** វេសយិ... **វសថ**, (**មយំ**) សយ... **វសាម**ៗ អាខ្យា... កត្តុ... **នគរស្ស** សាមិ... **សមីបេ**ៗ សមីបា... **វសាម** ។

ផ្លែទ. នៃស្វាយជ្រុះចុះចាកមែក ។ ទារកទ. ដណ្តើមនូវផ្លែស្វាយទ.នោះ ។

**អម្ពស្ស** សាមិ... **ផលានិ**ៗ សយ... **បតន្តិ**ៗ អាខ្យា... កត្តុ... **សាខាយ** អបា... **បតន្តិ** , **ទារកា** សយ... **វិលុម្បន្តិ**ៗ អាខ្យា... កត្តុ... **តានិ** វិសេ... (**អម្ពផលានិ**)ៗ អវុត្ត... **វិលុម្បន្តិ** ។

## ៧. ខេមរបរិវត្តន៍

**- ពុទ្ធោ ជនានំ ហិតាយ សុខាយ ធម្មំ ទេសេតិ** ។

**ពុទ្ធោ** សយ... **ទេសេតិ**ៗ អាខ្យា... កត្តុ... **ជនានំ** សម្បទា... **ហិតាយ** និង **សុខាយ**ៗ សម្បទា... **ទេសេតិ** , **ធម្មំ** អវុត្ត... **ទេសេតិ** ។

- **យេ ជនា សក្កច្ចំ បដិបជ្ជន្តិ , តេ ទុក្ខា បមុញ្ចន្តិ** ។

**យេ** វិសេ... **ជនា**ៗ សយ... **បដិបជ្ជន្តិ**ៗ អាខ្យា... កត្តុ... **សក្កច្ចំ** កិរិយាវិសេ... **បដិបជ្ជន្តិ** , **តេ** វិសេ... (**ជនា**)ៗ សយ... **បមុញ្ចន្តិ**ៗ អាខ្យា... កត្តុ... **ទុក្ខា** អបា... **បមុញ្ចន្តិ** ។

- **យោ អត្តានំ សញ្ញមតិ , សោ បាបា វិរមតិ** ។

**យោ** វិសេ... (**បុគ្គលោ**) សយ... **សញ្ញមតិ**ៗ អាខ្យា... កត្តុ... **អត្តានំ** អវុត្ត... **សញ្ញមតិ** , **សោ** វិសេ... (**បុគ្គលោ**)ៗ សយ... **វិរមតិ** , **បាបា** អបា... **វិរមតិ**ៗ អាខ្យា... កត្តុ... ។

- **យស្ស ធម្មេ បសាទោ អត្ថិ , សោ តំ ធម្មំ ចរតិ** ។

**យស្ស** វិសេ... (**បុគ្គលស្ស**)ៗ សាមិ... **បសាទោ** , **ធម្មេ** ព្យាបិកា... **បសាទោ**ៗ សយ... **អត្ថិ**ៗ អាខ្យា... កត្តុ..., **សោ** វិសេ... ( **បុគ្គលោ**)ៗ សយ... **ចរតិ** , **តំ** វិសេ... **ធម្មំ**ៗ អវុត្ត... **ចរតិ**ៗ អាខ្យា... កត្តុ...។

- **ចត្តារោ សេដ្ឋិនោ បុត្តា ហោន្តិ តេសុ ឯកោ មរតិ** ។

**ចត្តារោ** វិសេ... **បុត្តា** , **សេដ្ឋិនោ** សាមិ... **បុត្តា**ៗ សយ... **ហោន្តិ**ៗ អាខ្យា... កត្តុ..., **តេសុ** វិសេ... **បុត្តេសុ**ៗ និទ្ធារណៈ... **ឯកោ** វិសេ... **បុត្តោ**ៗ និទ្ធារណីយ និងជា សយ... **មរតិ**ៗ អាខ្យា... កត្តុ... ។

- **យោ បាបំ ករោតិ, តំ បាបំ តស្ស វិបាកំ ទេតិ** ។

**យោ** វិសេ... (**បុគ្គលោ**)ៗ សយ... **ករោតិ** , **បាបំ** អវុត្ត... **ករោតិ**ៗ អាខ្យា... កត្តុ... , **តំ** វិសេ... **បាបំ**ៗ សយ... **ទេតិ** , **តស្ស** វិសេ... (**បុគ្គលស្ស**)ៗ សម្ប... **ទេតិ**ៗ អាខ្យា... កត្តុ... **វិបាកំ** អវុត្ត... **ទេតិ** ។

- **ភិក្ខូ វិហារេ ធម្មំ សជ្ឈាយន្តិ** ។

**ភិក្ខូ** សយ... **សជ្ឈាយន្តិ** , **វិហារេ** វេសយិ... **សជ្ឈាយន្តិ** , **ធម្មំ** អវុត្ត... **សជ្ឈាយន្តិ**ៗ អាខ្យា... កត្តុ... ។

-**គិលានោ សយនេ និបជ្ជតិ វេជ្ជោ តស្ស ភេសជ្ជំ ទេតិ** ។

**គិលានោ** សយ... **និបជ្ជតិ** , **សយនេ** ឱបសិលេ... **និបជ្ជតិ**ៗ អាខ្យា... កត្តុ... , **វេជ្ជោ** សយ... **ទេតិ** , **តស្ស**

សម្ប... **ទេតិ** , **តេសដ្ឋំ** អវុត្ត... **ទេតិ**ៗ អាខ្យា... កត្តុ...។

- **ព្រាហ្មណា លាភាយ អគ្គិនោ រាសឹ បូជេន្តិ** ។

**ព្រាហ្មណា** សយ... **បូជេន្តិ** , **លាភាយ** សម្ប... **បូជេន្តិ** , **អគ្គិនោ** សាមិ... **រាសឹ**ៗ អវុត្ត... **បូជេន្តិ**ៗ អាខ្យា... កត្តុ... ។

- **សប្បុរិសា បសាទេន តីណិ រតនានិ បូជេន្តិ** ។

**សប្បុរិសា** សយ... **បូជេន្តិ** , **បសាទេន** ករណ... **បូជេន្តិ** , **តីណិ** វិសេ... **រតនានិ**ៗ អវុត្ត... **បូជេន្តិ**ៗ អាខ្យា... កត្តុ... ។

## ៨. បាលិបរិវត្តន៍

ព្រះរាជារមែងជាឥស្សរៈ នៃជនទាំងឡាយក្នុងរដ្ឋរបស់ខ្លួន។

**រាជា** បកតិកត្តាក្នុង **ហោតិ**ៗ អាខ្យា...កត្តុ... **អត្តនោ** សាមិ... **រដ្ឋេ**ៗ វេសយិ... **ជនានំ**ៗ សាមិ... **ឥស្សរោ**ៗ វិកតិ... **ហោតិ** ។

ទារកនេះជាចៅរបស់សេដ្ឋី ។

**អយំ** វិសេ... **ទារកោ**ៗ បកតិ... **ហោតិ**ៗ អាខ្យា...

កត្តុ... **សេដ្ឋិនោ** សាមិ... **នត្ថា**ៗ វិកតិ... **ហោតិ** ។

ព្រះពុទ្ធតែងជាទីពឹងរបស់សត្វទាំងឡាយ ។

**ពុទ្ធោ** បកតិ... **ហោតិ**ៗ អាខ្យា... កត្តុ... **សត្តានំ** សាមិ... **នាថោ**ៗ វិកតិ... **ហោតិ** ។

ព្រះធម៌រមែងជាទីពឹង ដ៏ខ្ពង់ខ្ពស់របស់យើងទាំងឡាយ ។

**ធម្មោ** បកតិ... **ហោតិ**ៗ អាខ្យា... កត្តុ... **នោ** ភាវាទិ... **សរណំ** , **ឧត្តមំ** វិសេ... **សរណំ**ៗ វិកតិ... **ហោតិ** ។

សង្ខារទ. ទាំងពួងជាធម៌មិនទៀង។ សង្ខារទ. ណាតែងកើតឡើង សង្ខារទ. នោះរមែងរលត់ទៅ ។

**សព្វេ** វិសេ... **សង្ខារា**ៗ បកតិ... **ហោន្តិ**ៗ អាខ្យា... កត្តុ.. **អនិច្ចា** វិកតិ... **ហោន្តិ** , **យេ** វិសេ... (**សង្ខារា**)ៗ សយ... **ឧប្បជ្ជន្តិ**ៗ អាខ្យា... កត្តុ... , **តេ** វិសេ... (**សង្ខារា**)ៗ សយ... **និរុជ្ឈន្តិ**ៗ អាខ្យា... កត្តុ... ។

សេចក្តីស្លាប់របស់សត្វទាំងឡាយទាំងពួងជាធម្មជាតិទៀង ។

**សព្វេសំ** វិសេ... **សត្តានំ**ៗ ភាវទិ... **មរណំ**ៗ បកតិ... **ហោតិ**ៗ អាខ្យា... កត្តុ... **និយតំ** (**ធុវំ**) វិកតិ... **ហោតិ** ។

សេចក្តីប្រមាទជាផ្លូវនៃសេចក្តីស្លាប់ ។

**បមាទោ** បកតិ... (**ហោតិ**)ៗ អាខ្យា... កត្តុ... **មច្ចុនោ** ភាវាទិ... **បទំ**ៗ វិកតិ... (**ហោតិ**) ។

ផ្លែទាំងឡាយរបស់សេដ្ឋីជាសត្វកាច ។

**សេដ្ឋិនោ** សាមិ... **សុនខា**ៗ បកតិ... **ហោន្តិ**ៗ អាខ្យា... កត្តុ... **ចណ្ឌា** វិកតិ... **ហោន្តិ** ។

នាងខ្ញុំជាស្ត្រីដល់ហើយ នូវព្រះពុទ្ធជាទីពឹង ។

**អហំ** បកតិ... **អស្មិ**ៗ អាខ្យា... កត្តុ... **ពុទ្ធំ** បកតិអវុត្ត... **គតា** , **សរណំ** វិកតិអវុត្ត... **គតា**ៗ វិកតិ... **អស្មិ** ។

## ៩. ខេមរបរិវត្តន៍

- **បិតា អម្ហាកំ បិយោ ហោតិ** ។

**បិតា** បកតិ... **ហោតិ**ៗ អាខ្យា... កត្តុ... **អម្ហាកំ** សាមិ... **បិយោ**ៗ វិកតិ... **ហោតិ** ។

- **អហំ មម មាតុយា បិយោ ហោមិ** ។

**អហំ** បកតិ... **ហោមិ**ៗ អាខ្យា... កត្តុ... **មម** សាមិ... **មាតុយា**ៗ សាមិ... **បិយា**ៗ វិកតិ... **ហោមិ** ។

- **បថវី សព្វេសំ សត្តានំ បតិដ្ឋា ហោតិ** ។

**បថវី** បកតិ... **ហោតិ**ៗ អាខ្យា... កត្តុ... **សព្វេសំ** វិសេ... **សត្តានំ**ៗ ភាវាទិ... **បតិដ្ឋា**ៗ វិកតិ... **ហោតិ** ។

- **អយំ មហន្តោ និគ្រោធោ ទេវតាយ អធិវុត្ថោ ហោតិ** ។

**និគ្រោធោ** បតកិ... **ហោតិ**ៗ អាខ្យា... កត្តុ... **អយំ** ក្តី **មហន្តោ** ក្តី វិសេ... **និគ្រោធោ** , **ទេវតាយ** អនភិហិ... **អធិវុត្ថោ**ៗ វិកតិ... **ហោតិ** ។

- **ឥទំ វចនំ តវ ឧបជ្ឈាយេន ភាសិតំ ហោតិ** ។

**វចនំ** បកតិ... **ហោតិ**ៗ អាខ្យា... កត្តុ... **ឥទំ** វិសេ... **វចនំ** , **តវ** សាមិ... **ឧបជ្ឈាយេន** អនភិហិ... **ភាសិតំ**ៗ វិកតិ... **ហោតិ** ។

- **ឥមានិ វត្ថានិ សទ្ធស្ស ទាយកេន ទិន្នានិ ហោន្តិ** ។

**វត្ថានិ** បកតិ... **ហោន្តិ** អាខ្យា... កត្តុ... **ឥមានិ** វិសេ...

**ចក្ខានិ** , **សច្ចស្ស** សម្បទា... **ទិន្នានិ** , **ទាយកេន** អនភិហិ... **ទិន្នានិ**ៗ វិកតិ... **ហោន្តិ** ។

- **ទលិទ្ទស្ស ធនំ ចោរេន គហិតំ ហោតិ** ។

**ធនំ** បកតិ... **ហោតិ**ៗ អាខ្យា... កត្តុ... **ទលិទ្ទស្ស** សាមិ... **ធនំ** , **ចោរេន** អនភិហិ... **គហិតំ**ៗ វិកតិ... **ហោតិ** ។

- **តុយ្ហំ បុត្តោ ពាលេន បហដោ ហោតិ** ។

**បុត្តោ** បកតិ... **ហោតិ**ៗ អាខ្យា... កត្តុ... **តុយ្ហំ** សាមិ... **បុត្តោ** , **ពាលេន** អនភិហិ... **បហដោ**ៗ វិកតិ... **ហោតិ** ។

- **សព្វេ កិលេសា អរហន្តេហិ បហីនា ហោតិ** ។

**កិលេសា** បកតិ... **ហោន្តិ**ៗ អាខ្យា... កត្តុ... **សព្វេ** វិសេ... **កិលេសា** , **អរហន្តេហិ** អនភិហិ... **បហីនា**ៗ វិកតិ... **ហោន្តិ** ។

- **អយំ ធម្មោ មុនីហិ អធិគតោ ហោតិ** ។

**ធម្មោ** បកតិ... **ហោតិ** អាខ្យា... កត្តុ... **អយំ** វិសេ... **ធម្មោ** , **មុនីហិ** អនភិហិ... **អធិគតោ**ៗ វិកតិ... **ហោតិ** ។

## ១០. បាលិបរិវត្តន៍

ស្រីនេះកាលបើស្វាមីរបស់ខ្លួន ស្លាប់ហើយ បានហើយនូវស្វាមីដទៃទៀត ។

**ឥត្ថី** សយ... **លភិ**ៗ អាខ្យា... កត្តុ... **អយំ** វិសេ... **ឥត្ថី**, **អត្តនោ** សាមិ... **សាមិកេ**ៗ លក្ខណៈក្នុង **មតេ**ៗ លក្ខណ-កិរិយា **អញ្ញំ** វិសេ... **សាមិកំ**ៗ អវុត្ត... **លភិ** ។

អ្នកគ្រូលាងអង្ករហើយ ដាក់ក្នុងឆ្នាំងហើយ អោយទឹករួចហើយលើកឡើងកាន់ចង្ក្រាន កាលបើភត្តឆ្អិនហើយដាក់ចុះហើយ ។

**សូទោ** សយ... **ឱតារេសិ**ៗ អាខ្យា... កត្តុ... **តណ្ឌុលំ** អវុត្ត... **ធោវិត្វា**ៗ បុព្វកាល... **បក្ខិបិត្វា**, **ឧក្ខលិយំ** បដិច្ឆន្នា... **បក្ខិបិត្វា**ៗ បុព្វកាល... **ទត្វា**, **ឧទកំ**, អវុត្ត... **ទត្វា**ៗ បុព្វកាល **ឱតារេសិ**, **ភត្តេ** លក្ខណៈ... **បក្កេ**ៗ លក្ខណកិរិយា ។

លោកអាចារ្យកាលវេលាដល់ព្រមហើយអោយឱវាទដល់សិស្សទ. របស់ខ្លួនហើយ ទើបចូលទៅកាន់បន្ទប់ ។

**អាចរិយោ** សយ... **បវិសតិ**ៗ អាខ្យា... កត្តុ... **វេលាយ** លក្ខណ... **សម្បត្តាយ**ៗ លក្ខណកិរិយា, **អត្តនោ** សាមិ... **សិស្សានំ** សម្ប... **ទត្វា** , **ឱវាទំ** អវុត្ត... **ទត្វា**ៗ បុព្វកាល... **បវិសតិ** , **គព្ភំ** សម្បាបុ... **បវិសតិ** ។

ចោរទ. ត្រាច់ទៅហើយក្នុងរាត្រី កាលបើអរុណរះឡើងហើយ រមែងចូលទៅកាន់ទីណាមួយហើយដេក ។

**ចោរោ** សយ... **សយន្តិ**ៗ អាខ្យា... កត្តុ... **រត្តិយំ** កាលត្ថស... **វិចរិត្វា**ៗ បុព្វកាល... **បវិសិត្វា** , **អរុណោ** លក្ខណ... **ឧគ្គតេ**ៗ លក្ខណកិរិយា , **អញ្ញតរំ** វិសេ... **ឋានំ**ៗ សម្បាបុ... **បវិសិត្វា**ៗ បុព្វកាល... **សយន្តិ** ។

ឧបាសកទ. ទៅកាន់អាវាសហើយថ្វាយនូវទានរួចហើយសមាទានសីលរួចស្តាប់ធម៌ ។

**ឧបាសកា** សយ... **សុណន្តិ**ៗ អាខ្យា... កត្តុ... **អាវាសំ** សម្បាបុ... **គន្ត្វា**ៗ បុព្វកាល... **ទត្វា** , **ទានំ** អវុត្ត... **ទត្វា**ៗ បុព្វកាល... **សមាទយិត្វា** , **សីលំ** អវុត្ត... **សមាទយិត្វា**ៗ បុព្វកាល... **សុណន្តិ** , **ធម្មំ** អវុត្ត... **សុណន្តិ** ។

ព្រះរាជា ស្តេចចេញចាកខាងក្នុងបុរីហើយ គង់នៅក្នុងសមាគមនៃអាមាត្យទ. ហើយទ្រង់ពិចាណាកិច្ចការដែលកើតឡើងហើយក្នុងដែនរបស់ខ្លួនរាល់ៗ ថ្ងៃ ។

**រាជា** សយ... **វិចារេតិ**ៗ អាខ្យា... កត្តុ... **ទិវសេ ទិវសេ** កាលត្ថ... **វិចារេតិ**, **អន្តេបុរា** អបាទា... **និក្ខមិត្វា**ៗ បុព្វកាល... **និសីទិត្វា** , **អមច្ចានំ** សាមិ... **សមាគមេ**ៗ អាធារ... **និសីទិត្វា**ៗ បុព្វកាល... **វិចារេតិ** , **អត្តនោ** សាមិ... **រដ្ឋេ**ៗ អាធារៈ... **ឧប្បន្នំ**ៗ វិសេ.... **កិច្ចំ**ៗ អវុត្ត... **វិចារេតិ** ។

ភិក្ខុមួយរូប ចូលទៅរកព្រះឧបជ្ឈាយ៍របស់ខ្លួនហើយ ថ្វាយបង្គំរួច អង្គុយលើអាសនៈដ៏សមគួរហើយសាកសួរនូវប្រស្នា ។

**ភិក្ខុ** សយ... **បុច្ឆិ**ៗ អាខ្យា... កត្តុ... **អញ្ញតរោ** វិសេ... **ភិក្ខុ** , **អត្តនោ**សាមិ... **ឧបជ្ឈាយំ**ៗ អវុត្ត... **ឧបសង្កមិត្វា**ៗ បុព្វកាល... **វន្ទិត្វា**ៗ បុព្វកាល... **និសីទិត្វា** , **បតិរូបេ** វិសេ... **អាសនេ**ៗ ឧបសិលេ... **និសីទិត្វា**ៗ បុព្វកាល... **បុច្ឆិ**, **បញ្ហំ** អវុត្ត... **បុច្ឆិ** ។

## ១១. ខេមរបរិវត្តន៍

- **មយ្ហំ តាត អាពាធោ គរុកោ ហោតិ, អវស្សំ មរិស្សាមិ មម មតស្ស តវ មាតរំ បោសេហិ** ។

**តាត** អាល... **អាពាធោ** បកតិ... **ហោតិ**ៗ អាខ្យា... កត្តុ... **មយ្ហំ** សាមិ... **អាពាធោ** , **គរុកោ** វិកតិ... **ហោតិ** (**អហំ** សយ...) **មរិស្សាមិ**ៗ អាខ្យា... កត្តុ... **អវស្សំ** កិ.វិ... **មរិស្សាមិ** , **មម** អនាទរៈ **មតស្ស**ៗ អនាទរកិ... (ត្វំ សយ...) **បោសេហិ**ៗ អាខ្យា... កត្តុ... **តវ** សាមិ... **មាតរំ**ៗ អវុត្ត... **បោសេហិ** ។

- **ឥធ សាសនេ អាវុសោ ទ្វេ ធុរានិ យោជេហិ** , **សចេ មម វចនេន ករោសិ ឥធ វុឌ្ឍឹ បាបុណិស្សសិ** ។

**អាវុសោ** អាល...(ត្វំ សយ...) **យោជេហិ**ៗ អាខ្យា... កត្តុ... **ឥធ** វិសេ... **សាសនេ**ៗ ភិន្នា... **ធុរានិ** , **ទ្វេ** វិសេ... **ធុរានិ**ៗ អវុត្ត... **យោជេហិ** , **សចេ**-សព្វ បរិកប្បត្ថ... (ត្វំ សយ...) **ករោសិ** អាខ្យា... កត្តុ... **មម** សាមិ... **វចនេន**ៗ តតិយាវិសេ... **ករោសិ** , (ត្វំ សយ...) **បាបុណិស្សសិ**ៗ អាខ្យា... កត្តុ... **ឥធ** វិសេ.... (**សាសនេ**)ៗ ភិន្នា... **វុឌ្ឍឹ**ៗ អវុត្ត.... **បាបុណិស្សសិ** ។

- **កថំ ភន្តេ ឥមស្ស វចនស្ស អត្ថោ** ។

**ភន្តេ** អាល... **កថំ**-សព្វ បុច្ឆនត្ថ **ឥមស្ស** វិសេ... **វចនស្ស**ៗ សាមិ... **អត្ថោ**ៗ លិង្គត្ថ: ។

- **កស្មា ត្វំ ភន្តេ ឯវំ ករោសិ** ។

**ភន្តេ** អាល... **ត្វំ** សយ... **ករោសិ**ៗ អាខ្យា... កត្តុ... **កស្មា** ហេតុ... **ករោសិ** , **ឯវំ** កិរិយាវិ... **ករោសិ** ។

- **អដ្ឋិមេ ភិក្ខវេ ធម្មា លោកំ អនុវត្តន្តិ**, **លោកោ ច អដ្ឋិមេ ធម្មេ អនុវត្តតិ** ។

**ភិក្ខវេ** អាល... **ធម្មា** សយ... **អនុវត្តន្តិ**ៗ អាខ្យា... កត្តុ... **អដ្ឋ** ក្តី **ឥមេ** ក្តី វិសេ... **ធម្មា** , **លោកំ** អវុត្ត... **អនុវត្តន្តិ**, **ច**-សព្វ សម្បិណ្ឌនត្ថ, **លោកោ** សយ... **អនុវត្តតិ**ៗ អាខ្យា... កត្តុ... **អដ្ឋ** ក្តី **ឥមេ** ក្តី វិសេ... **ធម្មេ**ៗ អវុត្ត... **អនុវត្តតិ** ។

- **កោ នាម ភន្តេ អយំ ធម្មោ** ? **អទិត្តបរិយាយោ នាម អាវុសោ** ។

**កោ** ក្តី **អយំ** ក្តី វិសេ... **ធម្មោ**, **នាម**-សព្វ សញ្ញាជោតិក: **កោ** , **ភន្តេ** សគារវា... **ធម្មោ** លិង្គត្ថ: **អាទិត្តបរិយាយោ** លិង្គត្ថ: **នាម**-សព្វ សញ្ញាជោតិក: **អាទិត្តបរិយាយោ** ,

**អាវុសោ** អគារវាលបន: ។

- **មា ត្វំ ឥតោ បដ្ឋាយ បុន ឥធាគច្ឆាហិ** ។

**ត្វំ** សយ... **អាគច្ឆាហិ**ៗ អាខ្យា... កត្តុ... **មា**-សព្ទ បដិសេធ... **អាគច្ឆាហិ**... **ឥតោ** អបាទាន... **បដ្ឋាយ**ៗ កិរិយាវិ... **អាគច្ឆាហិ** , **បុន**-សព្ទ កិរិយាវិ... **អាគច្ឆាហិ**... **ឥធ** វិសេ... **ឋានេ**ៗ ឧបសិលេ... **អាគច្ឆាហិ** ។

- **មា អាយស្មា សមគ្គស្ស សង្ឃស្ស ភេទាយ បរក្កមិ** ។

**អាយស្មា** សយ... **បរក្កមិ**ៗ អាខ្យា... កត្តុ... **មា**-សព្ទ បដិសេធ... **បរក្កមិ**, **សមគ្គស្ស**វិសេ... **សង្ឃស្ស**ៗ ឆដ្ឋីកម្ម... **ភេទាយ**ៗ សម្ប... **បរក្កមិ** ។

- **កឹ មយា សទ្ធឹ នទិយា បារំ គច្ឆិស្សសិ** ។

(**ត្វំ** សយ...) **គច្ឆិស្សសិ**ៗ អាខ្យា... កត្តុ... **កឹ**-សព្ទ បុច្ឆនត្ថ, **មយា** សហាត្ថត... **សទ្ធឹ**ៗ កិរិយាសមវាយ:... **គច្ឆិស្សតិ** , **នទិយា** សាមិ... **បារំ**ៗ សម្បាបុ... **គច្ឆិស្សសិ** ។

- **មា កិលេសា អត្តនោ វសេ វោ វត្តាបេន្តុ** ។

**កិលេសា** ហេតុកត្តា... **វត្តាបេន្តុ** អាខ្យា... ហេតុកត្តុ...

**មា**-សព្ទ បដិសេធ... **ឧត្តាបេន្តុ** , **អត្តនោ** សាមិ... **ឧសេ** ឧបសិលេ... **ឧត្តាបេន្តុ** , **ខោ** ការិត... **ឧត្តាបេន្តុ** ។

## ១២. បាលិបរិវត្តន៍

ម្នាលភិក្ខុទ. តថាគតនិងសំដែងធម៌ដល់លោកទ. ចូរលោកទ. ស្តាប់នូវធម៌ទ.នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃ តថាគតនឹងសំដែង ។

**ភិក្ខវេ** អាល... **អហំ** សយ... **ទេសេស្សាមិ**ៗ អាខ្យា... កត្តុ... **ធម្មំ** អវុត្ត... **ទេសេស្សាមិ** , **ខោ** សម្ប... **ទេសេស្សាមិ**, **តុម្ហេ** សយ... **សុណាថ** និង **ករោថ**ៗ អាខ្យា... កត្តុ... **តេ** វិសេ... **ធម្មេ**ៗ អវុត្ត... **សុណាថ** , **សាធុកំ** កិរិយាវិសេ... **ករោថ** , **មនសិ** អាធារ... **ករោថ** , **អហំ** សយ... **ភាសិស្សាមិ**ៗ អាខ្យា... កត្តុ... ។

បុគ្គលណាធ្វើបុណ្យយឺតយូរ បុគ្គលនោះ រមែងបាននូវផលយឺតយូរ ។

**បុគ្គលោ** សយ... **ករោតិ**ៗ អាខ្យា... កត្តុ... **យោ** វិសេ... **បុគ្គលោ** , **ទន្ធំ** កិរិយាវិសេ... **ករោតិ** , **បុញ្ញំ** អវុត្ត...

**ករោតិ បុគ្គលោ** សយ... **លភតិ**ៗ អាខ្យា.. កត្តុ... **សោ** វិសេ...
**បុគ្គលោ**, **ឥទ្ធំ** កិរិយាវិសេ... **លភតិ** , **ទិបាកំ** អវុត្ត... **លភតិ** ។

ដុំបាយក្នុងរោងទានមួយដង គឺភិក្ខុមិនឈឺគប្បីឆាន់, ប្រសិនបើភិក្ខុអង្គណា គប្បីឆាន់លើសជាងនោះ, អាបត្តិ-បាចិត្តិយ ( គប្បីមានដល់ ភិក្ខុអង្គនោះ) ។

**អាវសថបិណ្ឌោ** វុត្តកម្ម... **ភុញ្ជិតព្វោ**ៗ កិត... កម្ម... **អគិលានេន** វិសេ... **ភិក្ខុនា**ៗ អនភិហិ... **ភុញ្ជិតព្វោ**, **យោ** វិសេ... **ភិក្ខុ** , **តតោ** អបាទា... **ភុញ្ជេយ្យ** , **ចេ**-សព្វ បរិកប្បត្ថ **ឧត្តរឹ** កិរិយាវិសេ... **ភុញ្ជេយ្យ**ៗ ។

**សា** វិសេ... **ឥត្ថី**ៗ សយ... **ទទតិ**ៗ អាខ្យា... កត្តុ... **សច្ចំ** កិរិយាវិសេ... **ទទតិ** , **តស្សា** សាមិ... **វចនំ**ៗ វុត្តកម្មំ... **ភាតព្វំ**ៗ កិត... កម្ម... **មយា** អនភិហិ... **ភាតព្វំ** ។

សមណកាលដើរទៅសន្សឹមៗ តាមប្រក្រតី ទើបសម ។

**សមណោ** សយ... **សោភតិ**ៗ អាខ្យា... កត្តុ... **ចកតិយា** គតិយាវិសេ... **គច្ឆន្តោ**ៗ អព្ភន្តរកិរិយា... **សមណោ**, **សណិកំ** កិរិយាវិសេ... **គច្ឆន្តោ** ។

បុរសមានបុណ្យរមែងចេះដឹងនូវធម៌ ដែលព្រះមាន-ព្រះភាគទ្រង់សម្ដែងហើយយ៉ាងឆាប់ ។

**បុរិសោ** សយ... **ជានាតិ**ៗ អាខ្យា... កត្តុ... **បុញ្ញវា** វិសេ... **បុរិសោ**, **ភគវតា** អនភិហិ... **ទេសិតំ**ៗ វិសេ... **ធម្មំ**ៗ អវុត្ត... **ជានាតិ** ។

កិរិយាប្រព្រឹត្តដេកហើយលក់ អស់ថ្ងៃទាំងមូលប្រសើរជាង, ការត្រិះរិះនូវអកុសល ពុំប្រសើរសោះឡើយ ។

**វរតរំ** កិរិយាវិសេ... **និទ្ទាយនំ** , **សកលំ** វិសេ... **ទិវសំ**ៗ អច្ចន្តសំយោគក្នុង **និបជ្ជិត្វា**ៗ បុព្វកាល... **និទ្ទាយនំ**ៗ លិង្គត្ថៈ, **ន**-សព្ទ បដិសេធក្នុង **វរំ** , **អកុសលស្ស** ឆដ្ឋីកម្មក្នុង **វិតក្កនំ**ៗ លិង្គត្ថៈ ។

## ចប់បែបរៀនភាសាបាលី

## ភាគទី ៤